# សៀវភៅជំនួយស្មារតី
# ស្តីពីដំណើរការពង្រឹង
# ការងារអភិបាលកិច្ចរបស់
# ក្រុមប្រឹក្សាឃុំ សង្កាត់

# មាតិកា

**សេចក្តីថ្លែងអំណរគុណ** ១

**អារម្ភកថា** ២

**១ - សេចក្តីផ្តើម** ៣

**២ - គោលបំណងនៃសៀវភៅជំនួយស្មារតី** ៣

**៣ - វចនាសម្ព័ន្ធនៃរដ្ឋបាលឃុំ សង្កាត់** ៤

**៤ - ដំណើរការពង្រឹងការងារអភិបាលកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់** ៥

៤.១ -គោលបំណង ៥

៤.២ -សារៈប្រយោជន៍ ៥

៤.៣ -អ្នកចូលរួម ៦

៤.៤ -ដំណើរការ ៦

ដំណើរការសង្ខេបនៃការពង្រឹងការងារអភិបាលកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ៧

ជំហានទី១ - ក្រុមប្រឹក្សាឃុំ សង្កាត់ ធ្វើការណែនាំដល់សហគមន៍ ៩

ជំហានទី ២ - ដំណើរការវាយតម្លៃ ២៥

ជំហានទី៣ - ការចាត់បញ្ហាអាទិភាព និងការរៀបចំផែនការសកម្មភាព ២៩

ជំហានទី៤ - ការអនុវត្តផែនការ និងការផ្តល់ព័ត៌មានត្រឡប់ ៣១

**ឯកសារភ្ជាប់**

១. បញ្ជីសំណួរសម្រាប់សហគមន៍វាយតម្លៃអភិបាលកិច្ចមូលដ្ឋាន ៣៣

២. បញ្ជីសំណួរសម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់វាយតម្លៃអភិបាលកិច្ចមូលដ្ឋាន ៣៧

៣. ទម្រង់ផែនការសកម្មភាពដើម្បីលើកកម្ពស់អភិបាលកិច្ចនៅមូលដ្ឋាន ៤៣

# សេចក្តីថ្លែងអំណរគុណ

ក្នុងដំណើរការរៀបរៀងសៀវភៅជំនួយស្មារតីស្តីពី **ដំណើរការពង្រឹងការងារអភិបាលកិច្ចរបស់ក្រុមប្រឹក្សា ឃុំ សង្កាត់** យើងមានការគាំទ្រ និងជ្រោមជ្រែងពីអ្នកពាក់ព័ន្ធជាច្រើន ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីធ្វើឱ្យសៀវភៅនេះលេចចេញជារូបរាងឡើង ។

ជាបឋម យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រុមប្រឹក្សាឃុំ សង្កាត់ គណៈកម្មការកៀរគរសហគមន៍ និងតំណាងអង្គការសហគមន៍មូលដ្ឋាននៅក្នុងខេត្តស្វាយរៀង ព្រៃវែង កំពង់ចាម កំពង់ធំ ពោធិសាត់ បាត់ដំបង តាកែវ និងខេត្តកណ្តាល ដែលបានចូលរួមអនុវត្តន៍ និងផ្តល់យោបល់កែលម្អលើសៀវភៅជំនួយស្មារតីនេះឱ្យមានលក្ខណៈសាមញ្ញងាយយល់ និងអាចអនុវត្តន៍បាន។ ជាមួយគ្នានេះ សូមកោតសរសើរចំពោះការចូលរួមយ៉ាងសកម្មពីសំណាក់ប្រជាពលរដ្ឋនៅក្នុងឃុំ សង្កាត់គោលដៅសាកល្បងទាំង ៣២ ក្នុងដំណើរការអនុវត្តន៍សាកល្បងឧបករណ៍វាយតម្លៃការងារអភិបាលកិច្ចជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ដែលទទួលបានលទ្ធផលប្រកបដោយផ្លែផ្កា ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់គណៈកម្មាធិការប្រតិបត្តិកម្មវិធីល្អ ក្រុមការងារនៃគណៈកម្មាធិការប្រតិបត្តិកម្មវិធីគាំទ្រកំណែទម្រង់រដ្ឋបាលមូលដ្ឋាន (កម្មវិធីល្អ) មន្ត្រីនាយកដ្ឋានរដ្ឋបាលមូលដ្ឋាននៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋានក្រសួងមហាផ្ទៃ និងតំណាងសម្ព័ន្ធភាពជាតិឃុំ សង្កាត់ដែលបានផ្តល់យោបល់កែលម្អលើខ្លឹមសារ និងយុទ្ធសាស្ត្រអនុវត្តន៍ដែលធ្វើឱ្យសៀវភៅនេះស្របទៅតាមបទដ្ឋាន និងទម្រង់បែបបទរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ។

សូមថ្លែងអំណរគុណចំពោះទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) ដែលបានផ្តល់ថវិកាសម្រាប់បោះពុម្ពសៀវភៅជំនួយស្មារតីនេះ ។ ព្រមជាមួយគ្នានេះក៏សូមថ្លែងអំណរគុណចំពោះថ្នាក់ដឹកនាំអង្គការផេកកម្ពុជា ប្រធានកម្មវិធី និងមន្ត្រីកម្មវិធីគាំទ្រកំណែទម្រង់រដ្ឋបាលមូលដ្ឋាន (កម្មវិធីល្អ) បុគ្គលិកអង្គការដៃគូកម្មវិធីល្អថ្នាក់ខេត្តដែលបានរៀបរៀងសៀវភៅនេះឡើង ជាជំនួយស្មារតីដល់ក្រុមប្រឹក្សាឃុំ សង្កាត់ គណៈកម្មការកៀរគរសហគមន៍ និងអង្គការសហគមន៍មូលដ្ឋានក្នុងការចូលរួមចំណែកពង្រឹងអភិបាលកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ តាមរយៈការផ្តល់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព មានការចូលរួម និងឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋ ។

## អារម្ភកថា

នៅក្នុងឆ្នាំ២០០២ ព្រះរាជាណាចក្រកម្ពុជាបានបោះជំហានទៅមុខក្នុងការអនុវត្តដំណើរការវិមជ្ឈការ និងវិសហមជ្ឈការដោយមានការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ទូទាំងប្រទេស សរុបចំនួន ១៦២១ ឃុំ សង្កាត់។ នៅក្នុងឆ្នាំ២០០៦ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាតាមរយៈក្រសួងមហាផ្ទៃបានចេញសេចក្តីណែនាំលេខ ០០៧ សណន ស្តីពីការវាយតម្លៃផ្ទៃក្នុងលើកិច្ចការឃុំ សង្កាត់សម្រាប់អាណត្តិទី១ ឆ្នាំ២០០២-២០០៧ ហើយបានអនុវត្តន៍ដំណើរការវាយតម្លៃផ្ទៃក្នុងលើកិច្ចការឃុំ សង្កាត់ ដែលជាមធ្យោបាយសម្រាប់វាស់វែងដំណើរការប្រតិបត្តិការរបស់ក្រុមប្រឹក្សា (ដោយមានការចូលរួមពីប្រជាពលរដ្ឋ តាមរយៈការស្ទង់មតិ) ជាប្រយោជន៍ដើម្បីធ្វើឱ្យមានភាពប្រសើរឡើងទៅលើការប្រតិបត្តិកិច្ចការរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។

ដើម្បីចូលរួមចំណែកគាំទ្រដល់ការអនុវត្តដំណើរការវិមជ្ឈការ និងវិសហមជ្ឈការនេះ កម្មវិធី**គាំទ្រកំណែទម្រង់រដ្ឋបាលមូលដ្ឋាន (លា)** ដែលអនុវត្តន៍ដោយអង្គការផេកកម្ពុជាសហការជាមួយអង្គការដៃគូថ្នាក់ខេត្តចាប់ពីឆ្នាំ ២០០៦ រហូតដល់ ២០១០ ដោយមានការគាំទ្រមូលនិធិពីទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីការអភិវឌ្ឍអន្តរជាតិ (USAID) បានសាកល្បងបង្កើតឧបករណ៍បំពេញបន្ថែមមួយហៅថា **ដំណើរការពង្រឹងការងារអភិបាលកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់**ប្រចាំឆ្នាំ ។ ឧបករណ៍នេះចងក្រងឡើងដោយផ្អែកលើឯកសារ និងបទពិសោធន៍មួយចំនួន ដូចជាការវាយតម្លៃផ្ទៃក្នុងលើកិច្ចការឃុំ សង្កាត់ បច្ចេកទេសនៃការប៉ាន់ប្រមាណតម្រូវការតាមបែបចូលរួម និងរួមបញ្ចូលបទពិសោធន៍ពី**សារិ** (SHARIQUE) ស្តីពីឧបករណ៍វាយតម្លៃដោយខ្លួនឯងសម្រាប់អភិបាលកិច្ចមូលដ្ឋានរបស់អង្គការមួយនៃប្រទេសបង់ក្លាដេស ។

ឧបករណ៍វាយតម្លៃដំណើរការពង្រឹងការងារអភិបាលកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ប្រចាំឆ្នាំនេះបានអនុវត្តន៍សាកល្បងជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ និងសហគមន៍ចំនួន ៣២ឃុំ នៅក្នុងខេត្តគោលដៅរបស់កម្មវិធីលាទាំង ៨ ។

## ១-សេចក្តីផ្តើម

តាមការស្រាវជ្រាវជាអន្តរជាតិអំពីកិច្ចការអភិបាលកិច្ចល្អបានបង្ហាញថា ការបង្កើតឱ្យមានយន្តការ និងឱកាសសម្រាប់ការចូលរួមពីសំណាក់ប្រជាពលរដ្ឋ និងតួអង្គពាក់ព័ន្ធនានាក្នុងការត្រួតពិនិត្យ និងវាយតម្លៃទៅលើការអនុវត្តតួនាទី ភារៈកិច្ច និងមុខងាររបស់រដ្ឋបាលមូលដ្ឋាន គឺមានសារៈសំខាន់ជាសារវន្ត និងផ្តល់ផលប្រយោជន៍យ៉ាងច្រើន ហើយបានបង្កើននូវទំនុកចិត្ត និងប្រសិទ្ធភាពនៃការសម្រេចចិត្ត ក៏ដូចជាធ្វើឱ្យកាន់តែប្រសើរឡើងនូវគុណភាពនៃការផ្តល់សេវាសាធារណៈ និងកិច្ចអភិវឌ្ឍន៍មូលដ្ឋានរបស់ខ្លួន។

សៀវភៅជំនួយស្មារតីស្តីពី **"ដំណើរការពង្រឹងការងារអភិបាលកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់"** គឺជាឧបករណ៍វាយតម្លៃមួយដែលក្រុមប្រឹក្សាឃុំ សង្កាត់ ប្រើប្រាស់សម្រាប់ធ្វើការវាយតម្លៃលើការបំពេញតួនាទី ភារកិច្ច និងមុខងាររបស់ឃុំ សង្កាត់ដោយមានការចូលរួមពីប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន ហើយការងារនេះគួរអនុវត្តយ៉ាងហោចណាស់ ១ឆ្នាំម្តង។ លទ្ធផលដែលទទួលបានពីការវាយតម្លៃនេះ គឺរួមចំណែកកែលម្អលើការអនុវត្តកិច្ចការនានារបស់ឃុំ សង្កាត់ឱ្យកាន់តែមានប្រសិទ្ធភាព និងឆ្លើយតបតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋ។

ឧបករណ៍នេះបានអនុវត្តន៍សាកល្បងនៅក្នុងឃុំ សង្កាត់ ចំនួន៣២ នៅក្នុងខេត្តក្រុងចំនួន៨ របស់កម្មវិធីល្អ។ តាមរយៈបទពិសោធន៍នៃការសាកល្បង កម្មវិធីល្អបានធ្វើការចងក្រង និងកែលម្អឧបករណ៍នេះឱ្យកាន់តែមានភាពងាយស្រួល ក្នុងគោលបំណងដើម្បីជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់ និងប្រជាពលរដ្ឋអាចធ្វើការឆ្លុះបញ្ចាំង និងវាយតម្លៃដោយខ្លួនឯងរួមគ្នាលើការបំពេញតួនាទី ភារកិច្ច និងមុខងាររបស់ឃុំ សង្កាត់ ដើម្បីអាចបន្តពង្រឹងការងារអភិបាលកិច្ច ក៏ដូចជាការលើកកម្ពស់គណនេយ្យភាព និងតម្លាភាពចំពោះប្រជាពលរដ្ឋនៅមូលដ្ឋាន។ ម្យ៉ាងវិញទៀត ក្រុមប្រឹក្សាឃុំ សង្កាត់ និងប្រជាពលរដ្ឋអាចរៀនសូត្រ និងស្វែងយល់ពីគ្នាទៅវិញទៅមក ដែលជាកត្តាយ៉ាងសំខាន់ក្នុងការបង្កើនភាពជឿជាក់ និងភាពជាដៃគូសម្រាប់ជម្រុញដំណើរការអនុវត្តន៍លទ្ធិប្រជាធិបតេយ្យនៅកម្ពុជា។

## ២ គោលបំណងនៃសៀវភៅជំនួយស្មារតី

សៀវភៅជំនួយស្មារតីនេះ បង្កើតឡើងដើម្បីជាឯកសារជំនួយស្មារតីដល់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងសហគមន៍ ក្នុងការវាយតម្លៃពីការបំពេញតួនាទី ភារកិច្ច និងមុខងាររបស់ឃុំ សង្កាត់ ដោយមានការចូលរួមពីគណៈកម្មការកៀរគរសហគមន៍ អង្គការសហគមន៍មូលដ្ឋាន និងប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ហើយជាឯកសារសម្រាប់ប្រជាពលរដ្ឋស្វែងយល់បន្ថែមពីកិច្ចការនៅក្នុងមូលដ្ឋានរបស់ខ្លួន។ សៀវភៅនេះអាចជាប្រយោជន៍ផងដែរសម្រាប់អង្គការ និងស្ថាប័ននានាដែលកំពុងប្រតិបត្តិការ ក្នុងវិស័យអភិបាលកិច្ចមូលដ្ឋាន ដើម្បីគាំទ្រដល់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងដំណើរការឆ្លុះបញ្ចាំងពីការបំពេញតួនាទី ភារកិច្ច និងមុខងាររបស់ឃុំ សង្កាត់និមួយៗ ។

## ៣- រចនាសម្ព័ន្ធនៃរដ្ឋបាលឃុំ សង្កាត់

- ប្រព័ន្ធនៃអភិបាលកិច្ចមូលដ្ឋានត្រូវអនុវត្តនៅថ្នាក់ឃុំ សង្កាត់ ។
- រដ្ឋបាលឃុំ សង្កាត់ មានតួនាទីជម្រុញ និងគាំទ្រការអភិបាលកិច្ចល្អដោយចាត់ចែងប្រើប្រាស់ធនធាននានាដែលមានប្រកបដោយចីរភាពសម្រាប់បំពេញសេចក្តីត្រូវការជាមូលដ្ឋានក្នុងឃុំ សង្កាត់របស់ខ្លួន បំរើប្រយោជន៍រួមរបស់ប្រជាពលរដ្ឋ និងគោរពផលប្រយោជន៍របស់ជាតិស្របតាមនយោបាយទូទៅរបស់រដ្ឋ ។
- ក្រុមប្រឹក្សាឃុំ សង្កាត់ជាអង្គការតំណាងប្រជាពលរដ្ឋក្នុងឃុំ សង្កាត់ និងមានបេសកកម្មបំរើផលប្រយោជន៍ទូទៅក្នុងឃុំ សង្កាត់របស់ខ្លួន ។
- ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវជ្រើសរើសឡើងតាមការបោះឆ្នោត ដោយប្រជាពលរដ្ឋនៃឃុំ សង្កាត់ស្របទៅតាមនីតិវិធីនៃច្បាប់ស្តីពីការជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។
- ក្រុមប្រឹក្សាឃុំ សង្កាត់មានអាណត្តិ ៥ឆ្នាំ ហើយត្រូវផុតអាណត្តិនៅពេលដែលមានក្រុមប្រឹក្សាថ្មីចូលកាន់តំណែង។
- សមាសភាពក្រុមប្រឹក្សាឃុំ សង្កាត់មាន ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ និងសមាជិក ។
- ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ជាមេឃុំ ចៅសង្កាត់ និងមានអ្នកជំនួយការពីររូបគឺជំទប់ទី១ ឬចៅសង្កាត់រងទី១ និងជំទប់ទី២ ឬចៅសង្កាត់រងទី២ ។

**រចនាសម្ព័ន្ធក្រុមប្រឹក្សាឃុំ សង្កាត់**



## ៤ ដំណើរការពង្រឹងការងារអភិបាលកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់

នៅក្នុងសៀវភៅនេះ ដំណើរការពង្រឹងការងារអភិបាលកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ សំដៅទៅលើដំណើរការវាយតម្លៃលើការអនុវត្តតួនាទី ភារកិច្ច និងមុខងាររបស់ឃុំ សង្កាត់ យ៉ាងហោចណាស់មួយឆ្នាំម្តង ដោយមានការចូលរួមពីប្រជាពលរដ្ឋ។ ដំណើរការនេះជាមធ្យោបាយមួយក្នុងចំណោមមធ្យោបាយសំខាន់ផ្សេងៗទៀតក្នុងការពង្រឹងអភិបាលកិច្ចមូលដ្ឋាន។

### ៤.១ គោលបំណង

ពង្រឹង និងធ្វើឱ្យប្រសើរឡើង លើការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងការផ្តល់សេវាសាធារណៈរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងការចូលរួម ។

### ៤.២ សារៈប្រយោជន៍

- រាល់បញ្ហា និងតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋត្រូវបានប្រមូល និងវិភាគគ្រប់ជ្រុងជ្រោយមុននឹងក្រុមប្រឹក្សាឃុំ សង្កាត់ធ្វើការសម្រេចចិត្ត ។
- យល់ពីគោលគំនិតអភិបាលកិច្ចមូលដ្ឋាន ការអភិវឌ្ឍ និងដំណើរការអនុវត្តន៍ការងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់។
- ជាឱកាសបញ្ចេញមតិយោបល់កែលម្អលើការអនុវត្តតួនាទី ភារកិច្ច និងមុខងាររបស់ឃុំ សង្កាត់ ដើម្បីពង្រឹងសេវាកម្មបំរើប្រជាពលរដ្ឋ។
- ជួយកែលម្អកិច្ចការនានារបស់ឃុំ សង្កាត់ ( *ផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ*) ។
- ក្រុមប្រឹក្សាឃុំ សង្កាត់ពង្រឹងការផ្តល់សេវាកម្ម ដើម្បី
    - ឆ្លើយតបទៅនឹងសេចក្តីត្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋ
    - មានគណនេយ្យភាពចំពោះសហគមន៍របស់ខ្លួន
    - មានតម្លាភាពនៅក្នុងការសម្រេចចិត្ត និងការចំណាយថវិកា។

## ៤.៣ អ្នកចូលរួម

### ក្រុមសហគមន៍



អ្នកតំណាងអង្គការ សហគមន៍មូលដ្ឋាន



គណៈកម្មការគៀរគរ សហគមន៍ - គកស



អ្នកជំនួញនៅមូលដ្ឋាន



យុវជន



តំណាងសាសនា ឬចាស់ទុំភូមិ



កសិករ / មេផ្ទះ



ប្រជាពលរដ្ឋសាមញ្ញ ជនជាតិភាគតិច

### រដ្ឋបាលឃុំ សង្កាត់



ជំទប់ទី១ ចៅសង្កាត់រងទី១



មេឃុំ ចៅសង្កាត់



ស្មៀនឃុំ សង្កាត់



សមាជិកក្រុម ប្រឹក្សាឃុំ សង្កាត់



អ្នកទទួលបន្ទុក កិច្ចការនារី និងកុមារ



ជំទប់ទី២ ចៅសង្កាត់រងទី២

## ៤.៤ ដំណើរការ

ដំណើរការនៃការអនុវត្តការពង្រឹងអភិបាលកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ចែកចេញជាបួនជំហានចំបងៗ។

# ដំណើរការសង្ខេបនៃការពង្រឹងការងារអភិបាលកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់

**ជំហានទី ១** ក្រុមប្រឹក្សាឃុំ សង្កាត់ ធ្វើការណែនាំដល់សហគមន៍

**ជំហានទី ២** ដំណើរការវាយតម្លៃ




**ជំហានទី ៣** ការចាត់បញ្ហាអាទិភាព និងការរៀបចំផែនការសកម្មភាព

**ជំហានទី ៤** ការអនុវត្តផែនការ និងការផ្តល់ព័ត៌មានត្រឡប់

# ជំពូកទី ១

## ក្រុមប្រឹក្សាឃុំ សង្កាត់ធ្វើការណែនាំដល់សហគមន៍

**គោលបំណងនៃដំណើរការណែនាំដល់សហគមន៍** នៅចុងបញ្ចប់នៃដំណើរការណែនាំអ្នកចូលរួម (ក្រុមប្រឹក្សាឃុំ សង្កាត់ គណៈកម្មការកៀរគរសហគមន៍ និងអង្គការសហគមន៍មូលដ្ឋាន) អាច

១. ពន្យល់បានពីខ្លឹមសារនៃការចូលរួម អភិបាលកិច្ចល្អ តួអង្គសំខាន់ៗដែលពាក់ព័ន្ធការងារអភិបាលកិច្ច សិទ្ធិរបស់ប្រជាពលរដ្ឋ និងភារកិច្ចនៃរដ្ឋបាលឃុំ សង្កាត់។

២. សម្របសម្រួលដំណើរការវាយតម្លៃលើការពង្រឹងការងារអភិបាលកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ដោយរួមបញ្ចូលការប្រើប្រាស់បញ្ជីសំណួរ និងការដាក់ពិន្ទុ ការចាត់អាទិភាពបញ្ហា ការរៀបចំផែនការសកម្មភាព និងដំណើរការអនុវត្តន៍ផែនការសកម្មភាព និងការផ្តល់ព័ត៌មានត្រឡប់។

**អ្នកទទួលខុសត្រូវ** ក្រុមប្រឹក្សាឃុំ សង្កាត់

**ដំណើរការ** ការរៀបចំមុន និងកំឡុងពេលដំណើរការណែនាំដល់សហគមន៍

## ការរៀបចំមុនដំណើរការណែនាំដល់សហគមន៍

ដើម្បីឱ្យដំណើរការណែនាំដល់សហគមន៍ទទួលបានលទ្ធផលល្អ ក្រុមប្រឹក្សាឃុំ សង្កាត់ចាំបាច់ត្រូវគិតគូរ និងត្រៀមរៀបចំការងារមួយចំនួនដូចខាងក្រោម

- កំណត់ពេលវេលា និងទីកន្លែងសមស្រប (ដូចជាសាលាឃុំ សង្កាត់ ទីវត្តអារាម) ។
- កំណត់ និងជ្រើសរើសអ្នកចូលរួមក្នុងចំណោម គណៈកម្មការកៀរគរសហគមន៍ និងអង្គការសហគមន៍មូលដ្ឋានចំនួនចន្លោះពី៩ទៅ១២នាក់ ដែលពួកគាត់អាចសម្របសម្រួលដំណើរការវាយតម្លៃការងារអភិបាលកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ថ្នាក់ភូមិ ។
- កំណត់ និងជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ចំនួនពីរនាក់ជាអ្នកសម្របសម្រួលដំណើរការណែនាំដល់សហគមន៍ ។
- ត្រៀមសម្ភារៈដូចជាក្រដាសផ្ទាំងធំ ហ្វឺតសរសេរក្តារខៀន បង់ស្អិត ឯកសារមេរៀន បញ្ជីសំណួរ ។ល ។
- ផ្តល់ព័ត៌មាន និងអញ្ជើញអ្នកចូលរួម (សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ និងស្មៀន គណៈកម្មការកៀរគរសហគមន៍ និងអង្គការសហគមន៍មូលដ្ឋាន) ។

### កំណត់សម្គាល់ !!!

គ.ក.ស មកពីពាក្យពេញ គណៈកម្មការកៀរគរសហគមន៍ ដែលបានបង្កើតឡើងតាមការបោះឆ្នោតដោយប្រជាពលរដ្ឋក្នុងឃុំ សង្កាត់គោលដៅរបស់កម្មវិធីគាំទ្រកំណែទម្រង់រដ្ឋបាលមូលដ្ឋាន (កម្មវិធីល្អ) ។



## កំឡុងពេលនៃដំណើរការណែនាំដល់សហគមន៍

នៅក្នុងកំឡុងពេលនៃដំណើរការណែនាំដល់សហគមន៍ ត.ក.ស អង្គការសហគមន៍មូលដ្ឋាន ចំនួនចន្លោះពី ៩ទៅ១២នាក់ ក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ និងស្មៀន នឹងចូលរួមកក្នុង ដំណើរការណែនាំដល់សហគមន៍ ដើម្បីឱ្យពួកគាត់យល់ច្បាស់ពីគោលបំណង និងសារៈប្រយោជន៍ នៃការចូលរួម ស្វែងយល់ពីគោលគំនិតអភិបាលកិច្ច ដំណើរការវាយតម្លៃ និងចេះពីរបៀប សម្របសម្រួលក្នុងដំណើរការវាយតម្លៃអភិបាលកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ប្រកបដោយ តម្លាភាព គណនេយ្យភាព និងការចូលរួមយ៉ាងសកម្មពីប្រជាពលរដ្ឋ។

### កំណត់សម្គាល់ !!!

**ក្រុមប្រឹក្សាគួរតែ**

- មានពិធីបើក និងបិទដំណើរការណែនាំដល់សហគមន៍
- បង្ហាញពីគោលបំណងនៃដំណើរការណែនាំដល់សហគមន៍ ដល់អ្នកចូលរួម (**សូមមើលនៅទំព័រទី ១៣**)



**ការណែនាំសម្រាប់អ្នកសម្របសម្រួលៈ**

- អ្នកសម្របសម្រួលគួរតែបង្ហាញគោលបំណងរបស់ឧបករណ៍ វាយតម្លៃការងារអភិបាលកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់មុន ចាប់ផ្តើមដំណើរការណែនាំដល់សហគមន៍
- បន្ទាប់មកបង្ហាញ និងពិភាក្សាលើប្រធានបទនៅទំព័របន្ទាប់

### គោលបំណងនៃការវាយតម្លៃការងារអភិបាលកិច្ចរបស់ឃុំ សង្កាត់

ពង្រឹង និងធ្វើឱ្យប្រសើរឡើងលើការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងការផ្តល់សេវា សាធារណៈរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពរបស់ ប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងការចូលរួម។

## ដំណើរការណែនាំផ្តោតលើប្រធានបទដូចខាងក្រោម

### 1 ការចូលរួម

- និយមន័យនៃការចូលរួម
- សារៈប្រយោជន៍នៃការចូលរួម

### 2 អភិបាលកិច្ច និងអភិបាលកិច្ចល្អ

### 3 តួអង្គសំខាន់ៗដែលពាក់ព័ន្ធការងារអភិបាលកិច្ចមូលដ្ឋាន

### 4 សិទ្ធិរបស់ប្រជាពលរដ្ឋ និងភារកិច្ចរដ្ឋបាលឃុំ សង្កាត់

៤.១ សិទ្ធិរបស់ប្រជាពលរដ្ឋ

៤.២ ភារកិច្ចរដ្ឋបាលឃុំ សង្កាត់

### 5 ការណែនាំពីដំណើរការវាយតម្លៃ

៥.១ របៀបប្រើបញ្ជីសំណួរ

៥.២ ដំណើរការវាយតម្លៃ

### 6 ការចាត់បញ្ហាអាទិភាព

### 7 ការរៀបចំផែនការសកម្មភាព

**1** 

# ការចូលរួម



### ការណែនាំសម្រាប់អ្នកសម្របសម្រួល

- ប្រើសំណួរបំផុសគំនិត
  ក- អ្វីទៅជាការចូលរួម?
  ខ- តើការចូលរួមផ្តល់សារៈប្រយោជន៍អ្វីខ្លះ?
- បន្ទាប់មកអ្នកសម្របសម្រួលបង្ហាញពីចម្លើយដែលបានរៀបចំទុក។

## អ្វីទៅជាការចូលរួម?

## តើការចូលរួមផ្តល់សារៈប្រយោជន៍អ្វីខ្លះ?



### ការចូលរួម

ជាដំណើរការដែលប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធចូលរួមគ្រប់ដំណាក់កាលនៃការអភិវឌ្ឍ ការអនុវត្តកិច្ចការរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងវាយតម្លៃលើការបំពេញតួនាទី ភារកិច្ច និងមុខងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់។ ប្រជាពលរដ្ឋក៏ចូលរួមផងដែរក្នុងការសម្រេចចិត្តលើការជ្រើសរើសបញ្ហា ការវិភាគបញ្ហា និងតម្រូវការ ការរៀបចំផែនការ ការអនុវត្តគម្រោង ការចាត់ចែង និងការត្រួតពិនិត្យវាយតម្លៃគម្រោង ហើយចូលរួមសម្រេចលើការបែងចែកផលប្រយោជន៍ប្រកបដោយសមធម៌។

### សារៈប្រយោជន៍នៃការចូលរួម

- **យល់ដឹង និងមានភាពជាម្ចាស់** អ្នកចូលរួមយល់ដឹង និងមានទស្សនៈដូចគ្នាពីកិច្ចការទាំងឡាយ និងមានភាពជាម្ចាស់ ។
- **កិច្ចការមានគុណភាព** ការចូលរួមក្នុងការរៀបចំ ការអនុវត្តការតាមដានគម្រោង និងគោលការណ៍ផ្សេងៗធ្វើឱ្យកិច្ចការទទួលបានជោគជ័យតាមតម្រូវការរបស់អ្នកទទួលផល ។
- **បង្ការជម្លោះ** គ្រប់អ្នកពាក់ព័ន្ធបានដឹង និងយល់ពីកិច្ចការ ។
- **ចំណេញពេលវេលា និងថវិកា**លើការអភិវឌ្ឍសហគមន៍ និងការទទួលបានសេវា ។
- **បង្កើនទំនុកចិត្ត**រវាងក្រុមប្រឹក្សាឃុំ សង្កាត់ និងប្រជាពលរដ្ឋ។

# ២ អភិបាលកិច្ច និងអភិបាលកិច្ចល្អ



**ការណែនាំសម្រាប់អ្នកសម្របសម្រួល**

- **ប្រើសំណួរបំផុស** អ្វីទៅជាអភិបាលកិច្ច? អ្វីទៅជាអភិបាលកិច្ចល្អ?
- ប្រមូលគំនិតរបស់អ្នកចូលរួម និងធ្វើការបំពេញបន្ថែមទៅលើចំនុចខ្វះខាត ។

និយមន័យសាមញ្ញ **អភិបាលកិច្ច** មានន័យថាការគ្រប់គ្រង និងការចាត់ចែងកិច្ចការ ។

## ដូចម្តេចដែលហៅថា អភិបាលកិច្ច?

អភិបាលកិច្ចគឺជាវិធីសាស្ត្រដែលរដ្ឋ ស្ថាប័ន អង្គភាពប្រើប្រាស់ក្នុងការគ្រប់គ្រងសេដ្ឋកិច្ច សង្គមកិច្ច និងសន្តិសុខ ដើម្បីបំរើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋ ។

## ដូចម្តេចដែលហៅថា អភិបាលកិច្ចល្អ?

អភិបាលកិច្ចល្អ ជាវិធីសាស្ត្រ ឬមធ្យោបាយដែលរដ្ឋ ស្ថាប័ន អង្គភាពប្រើប្រាស់ក្នុងការគ្រប់គ្រងសេដ្ឋកិច្ច សង្គមកិច្ច និងសន្តិសុខ ដើម្បីបំរើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋដោយបំពេញបាននូវគោលការណ៍ចំនួន៨ រួមមាន *ការចូលរួម នីតិរដ្ឋ តម្លាភាព ការព្រមព្រៀងឯកភាពគ្នា សមធម៌ ប្រសិទ្ធភាពខ្ពស់ គណនេយ្យភាព និងការឆ្លើយតប* ។

**នីតិរដ្ឋ** ក្នុងន័យអភិបាលកិច្ចល្អទាមទារឱ្យមានឯកសារក្របខ័ណ្ឌច្បាប់គ្រប់គ្រាន់ ដើម្បីបម្រើ និងការពារ ផលប្រយោជន៍សាធារណៈ ហើយច្បាប់ទាំងនោះត្រូវបានអនុវត្តន៍ដោយមិនលម្អៀង ។

**ការព្រមព្រៀងឯកភាពគ្នា** ជាការពិចារណាទូលំទូលាយ និងវែងឆ្ងាយលើផលប្រយោជន៍ និងតម្រូវការរបស់អ្នកពាក់ព័ន្ធ ផ្សេងៗគ្នានៅក្នុងសង្គម ហើយឈានទៅរកការសម្រេចចិត្ត ដោយមានការព្រមព្រៀងឯកភាពគ្នាលើជម្រើស និងវិធីសាស្ត្រណាមួយដែលបម្រើផលប្រយោជន៍រួមសម្រាប់សហគមន៍ទាំងមូល ។

**សមធម៌** មានន័យថាក្រុម ឬជនគ្រប់រូបនៅក្នុងសហគមន៍ ជាពិសេសក្រុមភាគតិច និងក្រុមដែលងាយរងគ្រោះ មានឱកាសគ្រប់គ្រាន់ក្នុងការចូលរួមបញ្ចេញយោបល់ លើកឡើងនូវតម្រូវការពិត អនុវត្តន៍សកម្មភាព និង ទទួលផលប្រយោជន៍សមស្រប ដើម្បីកែលម្អ និងថែរក្សាសុខុមាលភាពរបស់ពួកគេ ។

**ប្រសិទ្ធភាពខ្ពស់** ជាដំណើរការ និងរចនាសម្ព័ន្ធគ្រប់គ្រងក្នុងការប្រើប្រាស់ធនធានឱ្យអស់លទ្ធភាព និងសន្សំសំចៃខ្ពស់ ដើម្បីបង្កើតលទ្ធផលដែលមានគុណភាពខ្ពស់ បរិមាណច្រើន អាចបម្រើផលប្រយោជន៍ជាអតិបរមា និងបាន ឆ្លើយតបទៅនឹងតម្រូវការពិតរបស់សង្គម ។

**ការឆ្លើយតប** ជាការព្យាយាមខិតខំប្រឹងប្រែងរបស់អង្គភាព ស្ថាប័ន ដើម្បីបម្រើប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធទាំងអស់ ដោយស្មើភាពគ្នា និងមិនរើសអើង នៅក្នុងក្របខ័ណ្ឌ ពេលវេលាមួយដ៏សមហេតុផល ។

កម្មវិធីគាំទ្រកំណែទម្រង់រដ្ឋបាលមូលដ្ឋាន(ល្អ) បានផ្តោតសំខាន់លើគោលការណ៍ ៤ គឺ **គណនេយ្យភាព ការចូលរួម ភាពជាដៃគូ និងតម្លាភាព** ។



**គណនេយ្យភាព** ការយល់ដឹងពីតួនាទី និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ពោលគឺក្រុមប្រឹក្សាឃុំ សង្កាត់ មានការទទួលខុសត្រូវប្រកបដោយការឆ្លើយតបទៅនឹងសំណូមពររបស់ប្រជាពលរដ្ឋ។



**ការចូលរួម** ប្រជាពលរដ្ឋ អង្គការសហគមន៍មូលដ្ឋាន និងសមាគមដទៃទៀតត្រូវបានភ្ជាប់ទំនាក់ទំនងជាមួយរដ្ឋបាលមូលដ្ឋាន ។




**ភាពជាដៃគូ** សង្គមស៊ីវិល ក្រុមប្រឹក្សាឃុំ សង្កាត់ រដ្ឋាភិបាល និងអ្នកពាក់ព័ន្ធផ្សេងទៀតធ្វើការរួមគ្នា ដើម្បីឱ្យសហគមន៍មានការរីកចម្រើនជាអតិបរមា ។




**តម្លាភាព** សាធារណជនអាចទទួលបានព័ត៌មានស្តីអំពីការសម្រេចចិត្ត សកម្មភាព និងការប្រើប្រាស់ថវិការបស់ក្រុមប្រឹក្សាឃុំ សង្កាត់។

# ៣ តួអង្គសំខាន់ៗដែលពាក់ព័ន្ធការងារអភិបាលកិច្ចមូលដ្ឋាន

### តើមានតួអង្គសំខាន់ៗណាខ្លះដែលពាក់ព័ន្ធការងារអភិបាលកិច្ចមូលដ្ឋាន?

ដើម្បីឱ្យការអនុវត្តអភិបាលកិច្ចមូលដ្ឋានមានដំណើរការល្អ គឺមិនមែនតម្រូវអោយមានតែតួអង្គក្រុមប្រឹក្សាឃុំ សង្កាត់តែមួយអនុវត្តនីកិច្ចការនោះទេ ចាំបាច់ត្រូវមានការចូលរួម និងមានទំនាក់ទំនងយ៉ាងជិតស្និទ្ធពីតួអង្គពាក់ព័ន្ធក្នុង និងក្រៅសហគមន៍ដទៃទៀតផងដែរ ជាពិសេសប្រជាពលរដ្ឋ។

**រដ្ឋបាលឃុំ សង្កាត់**






### ទំនាក់ទំនងរវាងតួអង្គសំខាន់ៗជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការងារអភិបាលកិច្ចមូលដ្ឋាន

ក្នុងដំណើរការអនុវត្តការងារអភិបាលកិច្ចមូលដ្ឋាន តួអង្គសំខាន់ៗទាំងអស់ចាំបាច់ត្រូវមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធ ដើម្បីជួយបំពេញអោយគ្នាទៅវិញទៅមកនូវចំនុចកង្វះខាតក្នុងការអភិវឌ្ឍសហគមន៍របស់ខ្លួន។ ការទំនាក់ទំនងនេះមានលក្ខណៈខុសគ្នាអាស្រ័យលើស្ថានភាពជាក់ស្តែងរបស់ឃុំ សង្កាត់និមួយៗ។ ការរកអោយឃើញនូវទំនាក់ទំនងនេះបានជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់ស្វែងយល់បន្ថែមទៀតពីសារៈប្រយោជន៍នៃតួអង្គនិមួយៗក្នុងការចូលរួមចំណែកជាធនធានសម្ភារៈ ថវិកា ពេលវេលា និងចំណេះដឹង ដើម្បីក្លាយជាដៃគូអភិវឌ្ឍន៍ក្នុងឃុំ សង្កាត់របស់ខ្លួន។

#### ការណែនាំសម្រាប់អ្នកសម្របសម្រួល



- **ប្រើសំណួរបំផុស** តើមានតួអង្គសំខាន់ៗណាខ្លះដែលពាក់ពន្ធ័ការងារអភិបាលកិច្ចមូលដ្ឋាន?
- តើអ្នកពាក់ព័ន្ធមានតួនាទីអ្វីខ្លះនៅក្នុងការងារអភិបាលកិច្ចនៅមូលដ្ឋាន?
- កត់ត្រារាល់គំនិតដែលអ្នកចូលរួមបានលើកឡើងនៅលើក្តារខៀន ឬក្រដាស់ផ្ទាំងធំ។
- អញ្ជើញអ្នកចូលរួម គូសបន្ទាត់ទំនាក់ទំនងរវាងតួអង្គនីមួយៗ ក្នុងស្ថានភាពជាក់ស្តែង ដោយការគូសបន្ទាត់ចុចៗ(.......)សម្រាប់ទំនាក់ទំនងខ្សោយ បន្ទាត់ស្តើង (———) សម្រាប់ទំនាក់ទំនងមធ្យម និងគូសបន្ទាត់ក្រាស់ (▬▬▬) សម្រាប់ទំនាក់ទំនងខ្លាំង ដោយប្រើពិណផ្សេងគ្នាពីទំនាក់ទំនងមួយទៅទំនាក់ទំនងមួយទៀត។

#### ឧទាហរណ៍នៃការទំនាក់ទំនង



# ៤ សិទ្ធិប្រជាពលរដ្ឋ និងភារកិច្ចរដ្ឋបាលឃុំ សង្កាត់

## ៤.១ សិទ្ធិប្រជាពលរដ្ឋ



### ការណែនាំសម្រាប់អ្នកសម្របសម្រួល

- បំផុសគំនិតដល់អ្នកចូលរួមដោយប្រើសំណួរ
  តើសិទ្ធិសំខាន់ៗរបស់ប្រជាពលរដ្ឋមានអ្វីខ្លះ?
  តើប្រជាពលរដ្ឋមានសិទ្ធិអ្វីខ្លះក្នុងការចូលរួមការងារអភិបាលកិច្ចមូលដ្ឋាន?
- កត់ត្រារាល់គំនិតយោបល់របស់អ្នកចូលរួមនៅលើក្ដារខៀន ឬ ក្រដាសផ្ទាំងធំ ។
- បញ្ជាក់បន្ថែមនូវចំនុចខ្វះខាត ។

**សិទ្ធិ ប្រជាពលរដ្ឋ**

- មានសិទ្ធិលើកសំណើ ឬធ្វើការប្ដឹងតវ៉ាជាលាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់ដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ហើយក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវឆ្លើយតបនឹងសំណើ ឬការប្ដឹងតវ៉ានោះ ។
- មានសិទ្ធិចូលរួមស្ដាប់រាល់កិច្ចប្រជុំសាធារណៈរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ប៉ុន្តែពុំមានសិទ្ធិអនុម័តទេ ។
- មានសិទ្ធិបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ដែលពួកគាត់គិតថាអាចតំណាងឱ្យផលប្រយោជន៍របស់ពួកគាត់បានប្រសើរបំផុត ។
- មានសិទ្ធិពិនិត្យតាមដានការអនុវត្តគម្រោងនៅក្នុងមូលដ្ឋានរបស់ខ្លួន ។
- មានសិទ្ធិចូលរួមទទួលបាននូវព័ត៌មានពីក្រុមប្រឹក្សាឃុំ សង្កាត់ ហើយពួកគាត់អាចទៅកាន់សាលាឃុំ សង្កាត់ ដើម្បីទទួលព័ត៌មានផ្សេងៗដែលខ្លួនចង់ដឹង ។



## ៤.២ ភារកិច្ចរដ្ឋបាលឃុំ សង្កាត់



**ការណែនាំសម្រាប់អ្នកសម្របសម្រួល**

- បំផុសគំនិតដល់អ្នកចូលរួមដោយប្រើសំណួរ

  តើកន្លងមករដ្ឋបាលឃុំ សង្កាត់បានបំពេញភារកិច្ចអ្វីខ្លះ?
- កត់ត្រារាល់គំនិតយោបល់របស់អ្នកចូលរួមនៅលើក្ដារខៀន ឬ ក្រដាសផ្ទាំងធំ ។
- បញ្ជាក់បន្ថែមនូវចំណុចខ្វះខាត ។




ការលើកកម្ពស់អភិបាលកិច្ចល្អនៅមូលដ្ឋាន គឺអាស្រ័យទៅលើតួអង្គក្រុមប្រឹក្សាឃុំ សង្កាត់ និងប្រជាពលរដ្ឋ ថាតើតួអង្គទាំងពីរបំពេញតួនាទីរបស់ខ្លួនបានប្រសើរកម្រិតណា ទន្ទឹមនឹងនោះការចូលរួមរបស់ប្រជាពលរដ្ឋជាផ្នែកមួយដ៏សំខាន់ ហេតុផលនេះហើយដែលប្រជាពលរដ្ឋត្រូវបានអញ្ជើញឱ្យចូលរួមវាយតម្លៃការងារអភិបាលកិច្ចនៅមូលដ្ឋាន ។

# 5 ការណែនាំពីដំណើរការវាយតម្លៃ

## ៥.១ របៀបប្រើបញ្ជីសំណួរ

ត្រូវជ្រើសយកសំណួរមួយពីក្នុងបញ្ជីសំនួរមកធ្វើជាគំរូក្នុងការពន្យល់ និងពិភាក្សាជាមួយអ្នកចូលរួម ដើម្បីយល់ពីខ្លឹមសារ និងរបៀបនៃការដាក់ពិន្ទុដោយប្រើនិមិត្តសញ្ញាដែលមានក្នុងបញ្ជីសំណួរ។ ***(បញ្ជីសំណួរនៅឯកសារភ្ជាប់ ១ និង២)***

## ៥.២ ដំណើរការវាយតម្លៃ

បែងចែកក្រុមពិភាក្សាជា២ក្រុម

**ត.ក.ស និងអង្គការសហគមន៍មូលដ្ឋាន**

បែងចែកអ្នកចូលរួមជាបីក្រុមពិភាក្សា ហើយសមាសភាពទាំងបីក្រុមនេះនឹងត្រូវបន្តសម្របសម្រួលដំណើរការវាយតម្លៃថ្នាក់ភូមិជាមួយប្រជាពលរដ្ឋ។

១- ជ្រើសរើសអ្នកសម្របសម្រួលចំនួន៣នាក់ (១នាក់ ក្នុង១ក្រុម)

២- ក្រុមនីមួយៗពិភាក្សាលើបញ្ជីសំណួរសម្រាប់សហគមន៍

៣- ក្រុមនីមួយៗជ្រើសរើសយកបញ្ហាសំខាន់ចំនួន៤ ដែលជាអាទិភាពចាំបាច់ ដើម្បីធ្វើការកែលម្អដោយផ្អែកលើនិមិត្តសញ្ញា (😊😐☹) ដែលមានក្នុងបញ្ជីសំណួរ

៤- ក្រុមនីមួយៗ សរសេរបំឡែងលទ្ធផលទាំង៤នោះ ទៅជាប្រយោគបញ្ហាវិញ ដោយសម្រួលន័យឱ្យងាយយល់ ហើយរក្សាបាននូវអត្ថន័យដើមនៃលទ្ធផលដែលក្រុមរកឃើញ

៥- បន្ទាប់មកក្រុមទាំង៣ ជួបប្រជុំគ្នាដើម្បីដាក់បញ្ចូលបញ្ហាសំខាន់ៗ និងពិនិត្យផ្ទៀងផ្ទាត់បញ្ហាទាំង១២រួមគ្នា។ ករណីរកឃើញបញ្ហាស្ទួនក្រុមចាត់ទុកជាបញ្ហាចំបង ហើយបញ្ហាដែលនៅសល់ត្រូវបន្តជ្រើសរើសតាមការបោះឆ្នោត។

៦- ជ្រើសរើស៦បញ្ហាចំបងក្នុងចំណោម១២បញ្ហាចំបង រួចសរសេរបញ្ហានីមួយៗលើក្រដាសរ៉ាមដាច់ពីគ្នាសម្រាប់ពិភាក្សាបន្តជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ។

**កំណត់សម្គាល់!!!**

នៅពេលអនុវត្តន៍ដំណើរការវាយតម្លៃនៅថ្នាក់ភូមិ ក្រុមពិភាក្សាត្រូវជ្រើសយកតំណាងប្រជាពលរដ្ឋ ៣នាក់ ១នាក់ (មួយក្រុម) ដែលសកម្មដើម្បីចូលរួមប្រជុំនៅថ្នាក់ឃុំ សង្កាត់។

**ក្រុមប្រឹក្សាឃុំ សង្កាត់**

១- ជ្រើសរើសអ្នកសម្របសម្រួលម្នាក់ក្នុងចំណោមសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

២- ពិភាក្សាគ្នាលើបញ្ជីសំណួរសម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់

៣-ជ្រើសរើសបញ្ហាចំបងចំនួន៦ ដែលជាអាទិភាពចាំបាច់ដើម្បីធ្វើការកែលម្អដោយផ្អែកលើនិមិត្តសញ្ញាដែលមានក្នុងបញ្ជីសំណួរ

៤- សរសេរបំឡែងបញ្ហាចំបងទាំង៦ នោះទៅជាប្រយោគបញ្ហាវិញដោយសម្រួលន័យឱ្យងាយយល់ ដោយរក្សាបាននូវអត្ថន័យដើមនៃលទ្ធផលដែលក្រុមរកឃើញ ហើយសរសេរបញ្ហានីមួយៗលើក្រដាសរ៉ាមដាច់ពីគ្នា។







### ការណែនាំសម្រាប់អ្នកសម្របសម្រួល

- មុននឹងដាក់ពិន្ទុសំណួរណាមួយ អ្នកសម្របសម្រួលក្រុមត្រូវប្រាកដថាអ្នកចូលរួមយល់ពីខ្លឹមសារសំណួរ ហើយការដាក់ពិន្ទុត្រូវឯកភាពគ្នា។ អ្នកសម្របសម្រួលត្រូវធ្វើយ៉ាងណាឱ្យអ្នកចូលរួមផ្តល់គំនិតយោបល់ជាក់ស្តែង ស្មោះត្រង់ ដោយមិនមានការភ័យខ្លាច ឬផ្គាប់ចិត្តនរណាម្នាក់ ហើយរាល់យោបល់ទាំងអស់ដែលបានលើកឡើងគឺជាលទ្ធផលរួមចំពោះការដាក់ពិន្ទុ។
- មុនពិភាក្សាពេញអង្គលើបញ្ហាអាទិភាព អ្នកសម្របសម្រួលចាំបាច់រំលឹកឡើងវិញពីគោលបំណងនៃការវាយតម្លៃការងារអភិបាលកិច្ចក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីឱ្យអ្នកចូលរួមមានការពេញចិត្តក្នុងការទទួលយកលទ្ធផលដែលរកឃើញ ។
- ជ្រើសរើសបញ្ហាអាទិភាពទៅតាមរូបភាព

  អាទិភាពទី១ ☹ ☹

  អាទិភាពទី២ ☹

  អាទិភាពទី៣ 😐

បញ្ហាដែលនៅសល់ត្រូវជ្រើសរើសតាមការបោះឆ្នោត

**ចំណាំ**

អ្នកសម្របសម្រួលគួរលើកទឹកចិត្តឱ្យក្រុមពិភាក្សាទាំងមូលពិចារណាលើ វិសាលភាពនៃបញ្ហាណាដែលផ្តល់ផលប្រយោជន៍ដោយផ្ទាល់ដល់សហគមន៍។

### ឧទាហរណ៍សម្រាប់ទាំងពីរក្រុម លទ្ធផលដែលជាបញ្ហាចម្បងសម្រាប់កែលម្អ

| | សំណួរ | ☺ ☺ | ☺ | 😐 | ☹ | ☹ ☹ |
|---|---|---|---|---|---|---|
| | តើចំណូល និងចំណាយថវិការបស់ឃុំ សង្កាត់បានបិទប្រកាសជាសាធារណៈដែរឬទេ? | | | | ✓ (ភាគតិច បានបិទ) | |
| | តើក្រុមប្រឹក្សាឃុំ សង្កាត់បានយកតម្លៃសេវាកម្មផ្សេងៗ លើសពីអត្រាតម្លៃដែលបានកំណត់ដោយរដ្ឋាភិបាលដែរឬទេ? | | | ✓ (ពេល ខ្លះយក) | | |

**បំប្លែងជាប្រយោគបញ្ហា :**

- ប្រជាពលរដ្ឋពុំបានដឹងអំពីចំណូលចំណាយថវិការបស់ឃុំ សង្កាត់
- ក្រុមប្រឹក្សាឃុំ សង្កាត់ **ពេលខ្លះយក** តម្លៃសេវាកម្មផ្សេងៗ លើសពីអត្រាតម្លៃដែលបានកំណត់ដោយរដ្ឋាភិបាល។



# ៦ ការចាត់បញ្ហាអាទិភាព



## កំណត់សម្គាល់ !!!

- ត្រូវជ្រើសរើសអ្នកសម្របសម្រួលកិច្ចប្រជុំនេះ ១នាក់ដែលមិនមែនជាមេឃុំ ឬ ចៅសង្កាត់ ។
- ការជ្រើសរើសបញ្ហាអាទិភាពអាចធ្វើឡើងដោយការបោះឆ្នោត ឬ តាមវិធីសមរម្យផ្សេងទៀតដែលអាចធ្វើទៅបាន ។

**ការណែនាំសម្រាប់អ្នកសម្របសម្រួល**

- ករណីលទ្ធផលបោះឆ្នោតលើសពី៨បញ្ហា (លេខស្មួន) អ្នកសម្របសម្រួលត្រូវបន្តចម្រាញ់ដោយប្រើប្រាស់វិធីសាស្ត្រណាមួយដែលសមស្របទៅតាមពេលវេលា ។
- អ្នកសម្របសម្រួលគួរលើកទឹកចិត្តគ.គ.ស ដោយកោតសរសើរចំពោះការចូលរួមដំណើរការវាយតម្លៃ ដើម្បីប្រមូលបញ្ហាពីសហគមន៍ ក្នុងគោលបំណងលើកកម្ពស់ការប្រតិបត្តិកិច្ចការរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

បន្ទាប់ពីក្រុមទាំងពីរជ្រើសបានបញ្ហាចំបងចំនួន ៦របស់ខ្លួន ក្រុមទាំងពីរមកជួបជុំគ្នាវិញដើម្បីកំណត់បញ្ហាអាទិភាពចំនួន ៨ មករៀបចំផែនការសកម្មភាព ដើម្បីលើកកម្ពស់ការប្រតិបត្តិកិច្ចការរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

**ដំណើរការនៃកិច្ចប្រជុំ**

១- អ្នកសម្របសម្រួលផ្តល់ឱកាសដល់ក្រុម គ.ក.ស និងអង្គការសហគមន៍មូលដ្ឋានបង្ហាញដោយសង្ខេបពីចំណុចអនុវត្តន៍បានល្អរបស់ក្រុមប្រឹក្សាឃុំ សង្កាត់មុននឹងបង្ហាញបញ្ហាចំបងទាំង ៦

២- បន្ទាប់មកតំណាងក្រុមប្រឹក្សាឃុំ សង្កាត់ បង្ហាញបញ្ហាចំបងទាំង ៦

៣- ដាក់បញ្ហាចំបងចម្រុះបញ្ចូលគ្នា ហើយអ្នកចូលរួមពិនិត្យបញ្ហាចំបងទាំង១២រួមគ្នា (*ករណីរកឃើញបញ្ហាដូចគ្នាចាត់ទុកជាបញ្ហាអាទិភាព*)

៤- បង់លេខរៀងលើបញ្ហាចំបងដោយចាប់ផ្តើមពីលេខ១

៥- បិទបញ្ហាចំបងទាំងនោះលើជញ្ជាំង ឬ ក្តារខៀន

៦- ចែកក្រដាសសម្រាប់បោះឆ្នោត

**ចំណាំ**

រាល់បញ្ហាទាំងអស់ដែលបានរកឃើញ ក្រុមប្រឹក្សាឃុំ សង្កាត់គួរដាក់បញ្ចូលក្នុងកម្មវិធីវិនិយោគឃុំ សង្កាត់ ។

៧- អញ្ជើញអ្នកចូលរួមទាំងអស់ពិនិត្យមើល និងជ្រើសរើសបញ្ហាអាទិភាពចំនួន៨ក្នុងម្នាក់ៗ ដោយសសេរតែលេខបញ្ហាអាទិភាពលើក្រដាសឆ្នោតដែលបានចែកជូន រួចយកទៅដាក់ក្នុងប្រអប់ឆ្នោត

៨- ជ្រើសរើសអ្នកស្ម័គ្រចិត្តចំនួន៣នាក់ (*គ.ក.ស១នាក់ តំណាងប្រជាពលរដ្ឋ១នាក់ និងក្រុមប្រឹក្សា ឃុំ សង្កាត់១នាក់*) ដើម្បីត្រួតពិនិត្យ និងរាប់សន្លឹកឆ្នោត ។

៩- អ្នកសម្របសម្រួលបូកសរុប និងបង្ហាញលទ្ធផលបញ្ហាអាទិភាពទាំង៨

# 7 ការរៀបចំផែនការសកម្មភាព

អ្នកសម្របសម្រួលបង្ហាញ និងពន្យល់ទម្រង់ផែនការសកម្មភាព ដើម្បីលើកកម្ពស់អភិបាលកិច្ចនៅមូលដ្ឋាន និងវិធីសាស្ត្រនៃដំណើរការរៀបចំផែនការសកម្មភាព ។

- យកបញ្ហាអាទិភាពទាំង៨ មកពិភាក្សា និងកំណត់សកម្មភាពអនុវត្តរួចបញ្ចូលលទ្ធផលដែលបានពិភាក្សា និងឯកភាពគ្នាទៅក្នុងទម្រង់ផែនការសកម្មភាព ដើម្បីលើកកម្ពស់អភិបាលកិច្ចនៅថ្នាក់មូលដ្ឋាន
- អញ្ជើញតំណាងគ.ក.ស អង្គការសហគមន៍មូលដ្ឋាន ឬតំណាងប្រជាពលរដ្ឋម្នាក់ឡើងមានចំណាប់អារម្មណ៍
- អញ្ជើញប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ឡើងមានចំណាប់អារម្មណ៍ និងប្តេជ្ញាចិត្តក្នុងការអនុវត្តផែនការសកម្មភាព ដើម្បីពង្រឹងការងារអភិបាលកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងមានមតិបិទកម្មវិធី ។



**សមាសធាតុនៅក្នុងផែនការលើកកម្ពស់អភិបាលកិច្ចនៅមូលដ្ឋាន**



១- **បញ្ហា** បញ្ហាអាទិភាពទាំង ៨ ដែលបានកំណត់

២- **ដំណោះស្រាយ** ជាសកម្មភាពមួយចំនួនដែលត្រូវលើកឡើងដើម្បីដោះស្រាយលើបញ្ហាដែលបានកំណត់

៣- **អ្នកទទួលខុសត្រូវ** មេឃុំ ឬចៅសង្កាត់ ជំទប់ ឬចៅសង្កាត់រង ស្មៀន ក្រុមប្រឹក្សាឃុំ សង្កាត់ គណៈកម្មការកៀរគរសហគមន៍ អង្គការសហគមន៍មូលដ្ឋាន ស្ថាប័នពាក់ព័ន្ធ

៤- **អ្នកគាំទ្រពីខាងក្រៅ** អ្នកគាំទ្រដល់ក្រុមប្រឹក្សាឃុំសង្កាត់ក្នុងការអនុវត្តដូចជា អង្គការដៃគូ ស្ថាប័នពាក់ព័ន្ធនានា

៥- **ថវិកា** ប្រភពថវិកាមួយចំនួនដូចជា មូលនិធិឃុំ សង្កាត់ ថវិកាបដិភាគ ថវិកាឧបត្ថម្ភពីស្ថាប័ននានា

៦- **ពេលវេលាកំណត់** ពេលចាប់ផ្តើមអនុវត្តន៍ និងពេលបញ្ចប់

៧- **ឯកសារភស្តុតាង** ឧទាហរណ៍ វិក័យប័ត្រ លិខិតអញ្ជើញ បញ្ជីឈ្មោះអ្នកចូលរួម កំណត់ហេតុរបាយការណ៍

## ឧទាហរណ៍ នៃទម្រង់ផែនការសកម្មភាព ដើម្បីលើកកម្ពស់អភិបាលកិច្ចនៅថ្នាក់មូលដ្ឋាន

| បញ្ហា | ដំណោះស្រាយ | អ្នកទទួលខុសត្រូវ | អ្នកគាំទ្រពីខាងក្រៅ | ថវិកា | ពេលវេលាកំណត់ | ឯកសារ ភស្តុតាង |
|---|---|---|---|---|---|---|
| ប្រជាពលរដ្ឋពុំបានដឹងអំពីចំណូល ចំណាយថវិការបស់ឃុំ សង្កាត់ | រៀបចំរបាយការណ៍ចំណូលចំណាយថវិកាប្រចាំខែ | - មេឃុំ ចៅសង្កាត់<br>- ក្រុមប្រឹក្សា<br>- ស្មៀន | គណនេយ្យករឃុំ សង្កាត់ នៅរតនាគារ មន្ត្រីសម្របសម្រួលស្រុកនៃកម្មវិធី គជអប | ទេ | រៀងរាល់ថ្ងៃទី ២៥ នៃខែនីមួយៗ | របាយការណ៍ចំណូលចំណាយថវិកាប្រចាំខែ |
| | ថតចំលងរបាយការណ៍ចំណូលចំណាយសម្រាប់ផ្សព្វផ្សាយ | ស្មៀន | ទេ | មូលនិធិឃុំ ផ្នែករដ្ឋបាល | រៀងរាល់ថ្ងៃទី ៣០ នៃខែនីមួយៗ | របាយការណ៍សម្រាប់បិទផ្សាយ |
| | បិទផ្សាយរបាយការណ៍លើក្តារព័ត៌មានឃុំ និងភូមិ | - ក្រុមប្រឹក្សា<br>- មេភូមិ<br>- គ ក ស | ទេ | ទេ | រៀងរាល់ថ្ងៃទី ០១ នៃខែនីមួយៗ | |
| | ផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំសាធារណៈក្នុងឃុំ សង្កាត់ | - ក្រុមប្រឹក្សា | ទេ | ទេ | គ្រប់កម្មវិធីប្រជុំសាធារណៈ | កំណត់ហេតុបញ្ជីវត្តមាន |
| ក្រុមប្រឹក្សាឃុំ សង្កាត់ពេលខ្លះ យកតម្លៃសេវាកម្មផ្សេងៗលើសពីការកំណត់របស់រដ្ឋាភិបាល | ក្រុមប្រឹក្សាឃុំ សង្កាត់ប្រជុំពិភាក្សាពិនិត្យឡើងវិញ និងសម្រេចយកតម្លៃសេវាកម្មជាក់លាក់តាមការកំណត់របស់រដ្ឋាភិបាល | ក្រុមប្រឹក្សា | អ្នកសម្របសម្រួលថ្នាក់ស្រុក | មូលនិធិឃុំ សង្កាត់ | ប្រជុំក្នុង ខែមករា ឆ្នាំ២០១០ | |
| | ផ្សព្វផ្សាយសាធារណៈនូវតម្លៃសេវាកម្មផ្សេងៗ តាមរយៈក្តារព័ត៌មាន មេភូមិ គ.ក.ស និងអង្គការសហគមន៍មូលដ្ឋាន | - ក្រុមប្រឹក្សា<br>- មេភូមិ<br>- គ.ក.ស<br>- អង្គការសហគមន៍មូលដ្ឋាន | ទេ | ទេ | ចាប់ពីខែ កុម្ភៈ ឆ្នាំ ២០១០ | |

# ជំពូកទី ២

## ដំណើរការវាយតម្លៃ

**គោលបំណង** វិភាគ និងកំណត់បញ្ហាចំបង ដើម្បីកែលម្អលើការបំពេញតួនាទី ភារកិច្ច និងមុខងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

**អ្នកទទួលខុសត្រូវ** ក្រុមប្រឹក្សាឃុំ សង្កាត់ និងតំណាងសហគមន៍

**ដំណើរការ** ការរៀបចំមុន និងកំឡុងពេលដំណើរការវាយតម្លៃ

## ការរៀបចំមុនដំណើរការវាយតម្លៃ

ដើម្បីឱ្យការអនុវត្តទទួលបានលទ្ធផលល្អ ក្រុមប្រឹក្សាឃុំ សង្កាត់ចាំបាច់ត្រូវគិតគូរ និងត្រៀមរៀបចំការងារមួយចំនួនដូចខាងក្រោម

- កំណត់ពេលវេលា (ពេលណាដែលប្រជាពលរដ្ឋភាគច្រើនអាចចូលរួមបាន) ។
- កំណត់ទីកន្លែងសមស្រប ដូចជាសាលាឃុំ ទីវត្តអារាម ។
- បែងចែកការទទួលខុសត្រូវដល់គណៈកម្មការកៀរគរសហគមន៍ និងអង្គការសហគមន៍មូលដ្ឋាន ដែលបានទទួលការណែនាំជាបីក្រុម (មួយក្រុមយ៉ាងតិច ៣នាក់) សម្រាប់ចុះសម្របសម្រួលដំណើរការវាយតម្លៃថ្នាក់ភូមិ ។ ចំពោះការវាយតម្លៃថ្នាក់ឃុំ សង្កាត់ត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំម្នាក់ ដើម្បីសម្របសម្រួលដំណើរការ ។
- រៀបចំឯកសារសម្រាប់បង្ហាញលើក្រដាសផ្ទាំងធំ ដូចជារបៀបវារៈ គោលបំណងវាយតម្លៃ បញ្ជីសំណួរ ទម្រង់ផែនការសកម្មភាព ។ល។
- ត្រៀមរៀបចំសម្ភារៈសម្រាប់ដំណើរការវាយតម្លៃដូចជា ក្រដាសផ្ទាំងធំ ហ្វឺត បង់ស្អិត
- ផ្តល់ព័ត៌មាន និងអញ្ជើញអ្នកចូលរួម (សម្រាប់ការវាយតម្លៃថ្នាក់ភូមិត្រូវអញ្ជើញអ្នកចូលរួមយ៉ាងតិច ៣០នាក់ ដែលមានបុរស និងស្ត្រី និងថ្នាក់ឃុំ សង្កាត់ គឺសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ និងស្មៀន) ។

ក្រុមប្រឹក្សាឃុំ សង្កាត់អាចអញ្ជើញតំណាងក្រុមប្រឹក្សាស្រុក ខណ្ឌ តំណាងមន្ទីរវិស័យ ស្ថាប័នពាក់ព័ន្ធ និងអង្គការនានា ចូលរួមក្នុងនាមជាអ្នកសង្កេតការណ៍ ។



# កំឡុងពេលដំណើរការវាយតម្លៃ

នៅដំណាក់កាលនេះមានកិច្ចប្រជុំពីរដាច់ដោយឡែកពីគ្នាគឺ កិច្ចប្រជុំរបស់សហគមន៍ និងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

## ១. កិច្ចប្រជុំរបស់សហគមន៍

តម្រូវអោយមានប្រជាពលរដ្ឋចូលរួមក្នុងមួយភូមិជាមធ្យមចំនួន៣០នាក់ ដោយមានសមាសភាពចំរុះដូចជា តំណាងយុវជន ស្ត្រី ក្រុមមិនសូវមានតំណាង ជនពិការ អ្នកផ្ទុកមេរោគអេដស៍ ជនជាតិដើមភាគតិច តំណាងសាសនា ចាស់ព្រឹទ្ធាចារ្យ និងតំណាងអង្គការសហគមន៍មូលដ្ឋាន ដើម្បីបង្កើនឱ្យមានការចូលរួមយ៉ាងសកម្ម និងការពិភាក្សាបានល្អិតល្អន់ពីគ្រប់អ្នកពាក់ព័ន្ធ។ ក្រុមប្រឹក្សាឃុំ សង្កាត់អញ្ជើញប្រជាពលរដ្ឋចូលរួមអនុវត្តន៍ដំណើរការនេះ ដោយប្រើវិធីសាស្ត្រជ្រើសរើសសំណាកតំរូដោយចៃដន្យ (ដើមភូមិ កណ្តាលភូមិ និងចុងភូមិ) ដើម្បីធានាថារាល់បញ្ហា និងតម្រូវការរបស់ប្រជាពលរដ្ឋត្រូវបានដាក់បញ្ចូលទូទាំងភូមិ។ គ.ក.ស និងអង្គការសហគមន៍មូលដ្ឋានដែលបានទទួលការណែនាំ ជាអ្នកដឹកនាំ និងសម្របសម្រួលការប្រជុំពិភាក្សានេះ។

**កំណត់សម្គាល់ !!!**

ការអញ្ជើញប្រជាពលរដ្ឋចូលរួមក្នុង ដំណើរការវាយតម្លៃការងារអភិបាលកិច្ចរបស់ឃុំ សង្កាត់ ចាំបាច់រៀបចំឡើងដោយរយៈពេលមួយសមស្រប មុនពេលចុះអនុវត្តជាក់ស្តែង ដោយជំរាបពួកគាត់ពីគោលបំណង ទីកន្លែង និងពេលវេលាជាក់លាក់ ។

### ដំណើរការកិច្ចប្រជុំរបស់សហគមន៍

១. អ្នកសម្របសម្រួលស្វាគមន៍ និងណែនាំខ្លួនដល់ប្រជាពលរដ្ឋ ។

២. បង្ហាញគោលបំណង និងសារៈប្រយោជន៍ចូលរួមការវាយតម្លៃការងារអភិបាលកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់

៣. ពន្យល់ដោយសង្ខេបពីគោលគំនិតអភិបាលកិច្ច តួអង្គសំខាន់ៗដែលពាក់ព័ន្ធការងារអភិបាលកិច្ចមូលដ្ឋាន សិទ្ធិរបស់ប្រជាពលរដ្ឋ និងភារកិច្ចនៃរដ្ឋបាលឃុំ សង្កាត់ ។ **(សូមមើលទំព័រទី ១៩ ដល់ទី ២២)**

៤. បែងចែកអ្នកចូលរួមជាបីក្រុម (មួយក្រុមប្រមាណ១០នាក់ដោយមានបុរស និងស្ត្រី) ហើយអ្នកសម្របសម្រួលក្នុងក្រុមនីមួយៗ ធ្វើការណែនាំពីរបៀបប្រើបញ្ជីសំណួរ ។

៥. ក្រុមនិមួយៗពិភាក្សាលើបញ្ជីសំណួរមួយម្តងៗ ដោយដាក់ពិន្ទុតាមនិមិត្តសញ្ញា 🙂 😐 🙁 រហូតដល់សំណួរចុងក្រោយ ។ មុននឹងដាក់ពិន្ទុសំណួរណាមួយ អ្នកសម្របសម្រួលត្រូវប្រាកដថាអ្នកចូលរួមយល់ពីខ្លឹមសារសំណួរ ហើយមានការឯកភាពគ្នាក្នុងការដាក់ពិន្ទុ ។

៦. ក្រុមនិមួយៗជ្រើសរើសបញ្ហាសំខាន់ចំនួន ៤ ជាអាទិភាពក្នុង១ក្រុម ហើយសរសេរបំឡែងបញ្ហាសំខាន់នោះជាប្រយោគបញ្ហា ដោយសម្រួលន័យឱ្យងាយយល់ ។

៧. អ្នកសម្របសម្រួលតាមក្រុមនីមួយៗ ត្រូវជ្រើសរើសតំណាងប្រជាពលរដ្ឋ ដែលសកម្មម្នាក់ ដើម្បីចូលរួមកិច្ចប្រជុំចាត់អាទិភាពបញ្ហា និងរៀបចំផែនការសកម្មភាពនៅសាលាឃុំ សង្កាត់ ។

៨. បន្ទាប់មកក្រុមទាំង៣ មកជួបប្រជុំគ្នា ដើម្បីដាក់បញ្ចូលបញ្ហាសំខាន់ដែលបានកំណត់ដោយក្រុមនិមួយៗ (សរុបបញ្ហាសំខាន់ចំនួន ១២) និងពិនិត្យផ្ទៀងផ្ទាត់បញ្ហាសំខាន់ចំនួន ១២

៩. ក្រុមទាំង៣បន្តពិភាក្សា និងកំណត់បញ្ហាចំបងចំនួន ៦ ជាអាទិភាពក្នុងចំណោមបញ្ហាសំខាន់ចំនួន ១២ រួចសរសេរបញ្ហាចំបងនិមួយៗលើក្រដាសរ៉ាមដាច់ពីគ្នាសម្រាប់យកទៅបង្ហាញ និងពិភាក្សាជាមួយក្រុមប្រឹក្សាឃុំ សង្កាត់

១០. ជ្រើសរើសអ្នកបង្ហាញបញ្ហាចំបងក្នុងពេលកិច្ចប្រជុំជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ដើម្បីចាត់បញ្ហាអាទិភាព។

## ២. កិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ និងស្មៀនចូលរួមកិច្ចប្រជុំវាយតម្លៃដំណើរការងារអភិបាលកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

### ដំណើរការកិច្ចប្រជុំពិភាក្សារបស់ក្រុមប្រឹក្សាឃុំ សង្កាត់

១. ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវអនុម័តលើការសម្រេចចិត្ត ក្នុងការជ្រើសរើសអ្នកសម្របសម្រួលម្នាក់ ក្នុងចំណោមសមាជិកក្រុមប្រឹក្សាដែល**មិនមែនជាមេឃុំ ឬចៅសង្កាត់ ។**

២. រំលឹកឡើងវិញអំពីខ្លឹមសារសំខាន់ៗដែលបានណែនាំនៅជំហានទី១ និងបញ្ជាក់ពីគោលបំណង សារៈប្រយោជន៍ នៃការចូលរួមដំណើរការពង្រឹងការងារអភិបាលកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ គោលគំនិតអភិបាលកិច្ច តួអង្គសំខាន់ៗដែលពាក់ព័ន្ធការងារអភិបាលកិច្ចមូលដ្ឋាន សិទ្ធិរបស់ប្រជាពលរដ្ឋ និងភារកិច្ចនៃរដ្ឋបាលឃុំ សង្កាត់។ **(សូមមើលទំព័រទី ១៥ ដល់ទី ២២)**

៣. ពិភាក្សាលើបញ្ជីសំណួរមួយម្តងៗ ដោយដាក់ពិន្ទុ តាមនិមិត្តសញ្ញា 🙂 😐 🙁 រហូតដល់សំណួរចុងក្រោយ ។ មុននឹងដាក់ពិន្ទុសំណួរណាមួយ អ្នកសម្របសម្រួលត្រូវប្រាកដថាអ្នកចូលរួមយល់ពីខ្លឹមសារសំណួរ ហើយមានការឯកភាពគ្នាក្នុងការដាក់ពិន្ទុ ។

៤. ជ្រើសរើសបញ្ហាចំបងចំនួន ៦ ជាអាទិភាព ។

៥. សរសេរបំឡែងបញ្ហាចំបងនោះទៅជាប្រយោគបញ្ហា ដោយសម្រួលន័យឱ្យងាយយល់ ។

៦. សរសេរបញ្ហាចំបងនិមួយៗលើក្រដាសរ៉ាមដាច់ពីគ្នាសម្រាប់យកទៅបង្ហាញ និងពិភាក្សាជាមួយក្រុមសហគមន៍ ។



# ជំពូកទី ៣

# ការចាត់បញ្ហាអាទិភាព និងការរៀបចំផែនការសកម្មភាព

## គោលបំណង

- បន្សុីបញ្ហាចំបងរបស់សហគមន៍ និងក្រុមប្រឹក្សាឃុំ និងចាត់អាទិភាពបញ្ហាសម្រាប់កែលម្អ
- រៀបចំផែនការសកម្មភាពឆ្លើយតបបញ្ហាអាទិភាព

**អ្នកទទួលខុសត្រូវ** ក្រុមប្រឹក្សាឃុំ សង្កាត់ និងតំណាងសហគមន៍

**ដំណើរការ** ការចាត់បញ្ហាអាទិភាព និងការរៀបចំផែនការសកម្មភាព

### ៣.១ ការចាត់បញ្ហាអាទិភាព

ជាជំហានដែលក្រុមប្រឹក្សាឃុំ សង្កាត់ គ.ក.ស អង្គការសហគមន៍មូលដ្ឋាន និងមានតំណាងប្រជាពលរដ្ឋចំនួន៣នាក់ (ដែលបានចូលរួមដំណើរការវាយតម្លៃថ្នាក់ភូមិ) ជួបប្រជុំពិភាក្សាគ្នានៅសាលាឃុំ សង្កាត់ ដើម្បីបង្ហាញលទ្ធផលនៃការវាយតម្លៃថ្នាក់ឃុំ សង្កាត់ និងថ្នាក់ភូមិ ហើយពិនិត្យ និងចាត់អាទិភាពបញ្ហាបន្ត ដោយកំណត់យកបញ្ហាអាទិភាពចំនួន៨ ក្នុងចំណោម ១២បញ្ហាចំបង។

**ដំណើរការចាត់បញ្ហាអាទិភាព សូមមើលឯកសារជំហានទី ១ ប្រធានបទទី ៦ ទំព័រទី ២៥ ។**



### ៣.២ ការរៀបចំផែនការសកម្មភាព

ជាជំហានដែលក្រុមប្រឹក្សាឃុំ សង្កាត់ គ ក ស អង្គការសហគមន៍មូលដ្ឋាន និងតំណាងប្រជាពលរដ្ឋរួមគ្នារៀបចំផែនការសកម្មភាពឆ្លើយតបនឹងបញ្ហាអាទិភាពទាំង៨ ដើម្បីលើកកម្ពស់អភិបាលកិច្ចមូលដ្ឋានដោយប្រើប្រាស់វិធីសាស្ត្រដូចបានរៀបរាប់ និងឧទាហរណ៍ក្នុង**ជំហានទី១ ប្រធានបទទី៧ ការរៀបចំផែនការសកម្មភាពនៅទំព័រទី ២៦ ដល់ ទំព័រទី ២៧ ។**

# ជំពូកទី ៤

## ការអនុវត្តផែនការសកម្មភាព និងការផ្ដល់ព័ត៌មានត្រឡប់

**ក្រោយពេលរៀបចំផែនការសកម្មភាព ដើម្បីលើកកម្ពស់អភិបាលកិច្ចមូលដ្ឋាន ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវ**

- ផ្សព្វផ្សាយផែនការសកម្មភាពដែលបានព្រមព្រៀងគ្នាជាសាធារណៈដល់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធផ្សេងទៀតតាមរយៈក្តារព័ត៌មាន និងកិច្ចប្រជុំផ្សេងៗ។
- អនុវត្តសកម្មភាពទៅតាមផែនការសកម្មភាពដែលបានព្រមព្រៀងគ្នា ។
- រាយការណ៍ជាប្រចាំអំពីសកម្មភាព និងលទ្ធផលបានអនុវត្តន៍នៅក្នុងកិច្ចប្រជុំប្រចាំខែ ឬកិច្ចប្រជុំនានាដោយមានការចូលរួមពី គ.ក.ស អង្គការសហគមន៍មូលដ្ឋាន ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធ។
- លើកផែនការបន្ត ជាប្រចាំតាមរយៈការប្រជុំប្រចាំខែ ដោយមាន គ.ក.ស អង្គការសហគមន៍មូលដ្ឋាន ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធចូលរួមអនុវត្តន៍ និងតាមដាន។
- ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវរក្សាទុកនូវឯកសារភស្តុតាង ឬឯកសារពាក់ពន្ធ័ការអនុវត្តសកម្មភាព ឧទាហរណ៍ កំណត់ហេតុ របាយការណ៍ បញ្ជីវត្តមាន រូបថត .......
- ក្រុមប្រឹក្សាឃុំ សង្កាត់ អាចអនុវត្តដំណើរការវាយតម្លៃការងារអភិបាលកិច្ចរបស់ខ្លួនរយៈពេល ៦ខែ ឬ ១ឆ្នាំម្តង ដើម្បីដោះស្រាយបញ្ហាបញ្ហា និងតម្រូវការរបស់សហគមន៍ឱ្យទាន់ពេល។



## កំណត់សម្គាល់ !!!

ក្រុមប្រឹក្សាឃុំ សង្កាត់អាចបន្ថែមបញ្ជីសំណួរទៅតាមភាពចាំបាច់នៃតម្រូវការជាក់ស្តែង ដោយមានការចូលរួមពិភាក្សាជាមួយតំណាងសហគមន៍ និងអ្នកពាក់ព័ន្ធ ។

## ឯកសារភ្ជាប់ទី ១

### បញ្ជីសំណួរសម្រាប់**សហគមន៍**វាយតម្លៃការងារអភិបាលកិច្ចមូលដ្ឋាន

**១.១. តើការចូលរួមរបស់ប្រជាពលរដ្ឋបានល្អដូចម្តេចដែរទាក់ទងនិងអភិបាលកិច្ចមូលដ្ឋាន?**

| លរ | សំណួរ | ☺☺ | ☺ | 😐 | ☹ | ☹☹ |
|---|---|---|---|---|---|---|
| ១ | តើប្រជាពលរដ្ឋមានការយល់ដឹងដូចម្តេចដែរចំពោះតួនាទី និងការទទួលខុសត្រូវរបស់អ្នកនៅក្នុងការចូលរួមអភិវឌ្ឍន៍ និងសកម្មភាពផ្សេងៗទៀតរបស់សហគមន៍? | ដឹងទាំងអស់ | ដឹងបានភាគច្រើន | ដឹងបានផ្នែកខ្លះ | ដឹងបានតិចតួច | មិនដឹងទាល់តែសោះ |
| ២ | តើអ្នកចូលរួមបានកំរិតណាក្នុងកិច្ចប្រជុំសាធារណៈរបស់ឃុំសង្កាត់ (ការប្រជុំភូមិ ប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងវេទិកាសាធារណៈ)? | ច្រើនណាស់ | ច្រើន | មធ្យម | ទាប | គ្មាន |
| ៣ | តើអង្គការសហគមន៍មូលដ្ឋាននៅក្នុងភូមិ ឃុំ សង្កាត់បាននាំសំឡេង និងតម្រូវការរបស់ប្រជាពលរដ្ឋទៅកាន់ឃុំ សង្កាត់បានកំរិតណា? | ខ្ពស់ណាស់ | ខ្ពស់ | មធ្យម | ទាប | គ្មាន |
| ៤ | តើក្រុមមិនសូវមានតំណាង និងប្រជាពលរដ្ឋក្រីក្រមានតំណាងរបស់ខ្លួន និងមានសំលេងនៅក្នុងអង្គការសហគមន៍មូលដ្ឋានដែរឬទេ? | ខ្ពស់ណាស់ | ខ្ពស់ | មធ្យម | ទាប | គ្មាន |
| ៥ | តើប្រជាពលរដ្ឋមានភាពសកម្មដូចម្តេចក្នុងការចរចារទាមទារពីតម្រូវការជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ និងជាមួយអ្នកដទៃទៀត? | ខ្ពស់ណាស់ | ខ្ពស់ | មធ្យម | ទាប | មិនមាន |

## ១.២.តើរដ្ឋបាលឃុំ សង្កាត់បំពេញតួនាទីរបស់ខ្លួនបានល្អដូចម្តេច?

| ល.រ | សំណួរ | ☺☺ | ☺ | 😐 | ☹ | ☹☹ |
|---|---|---|---|---|---|---|
| ៦ | តើសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់បានបំពេញតួនាទី និងការទទួលខុសត្រូវរបស់ខ្លួនល្អដែរឬទេ? | ល្អណាស់ | ល្អភាគច្រើន | ល្អផ្នែកខ្លះ | បានតិចតួចណាស់ | មិនបានទាល់តែសោះ |
| ៧ | តើការប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ធ្វើឡើងទៀងទាត់ដែរឬទេ? | ធ្វើជារៀងរាល់ខែ | ភាគច្រើន ១០-១១ ក្នុងមួយឆ្នាំ | ពេលខ្លះ ៦-៩ ក្នុង១ឆ្នាំ | កម្រ ១-៥ ក្នុង១ឆ្នាំ | មិនដែលមាន |
| ៨ | តើក្រុមប្រឹក្សាឃុំ សង្កាត់បានផ្សព្វផ្សាយពីលទ្ធផលនៃការប្រជុំខែកន្លងមកដល់សាធារណជនដែរឬទេ? | តែងតែធ្វើ | ភាគច្រើនបានធ្វើ | ធ្វើពេលខ្លះ | កម្រធ្វើ | មិនដែលធ្វើ |
| ៩ | តើក្រុមប្រឹក្សាឃុំ សង្កាត់បានផ្សព្វផ្សាយដែរឬទេអំពីប្រធានបទ របៀបវារៈ និងកាលវិភាគប្រជុំ (តាមរយៈក្តារព័ត៌មានភូមិ-ឃុំ សមាជិកគ.ក.ស និងប្រធានភូមិ)? | តែងតែប្រកាស | ភាគច្រើនបានប្រកាស | ពេលខ្លះបានប្រកាស | កម្រប្រកាស | មិនដែលប្រកាស |
| ១០ | តើសាលាឃុំ សង្កាត់ បើកបំរើការងារជាទៀងទាត់ដែរឬទេ? | បើករាល់ថ្ងៃ និងទាន់ពេល | បើកបួនថ្ងៃក្នុង១សប្តាហ៍ | បើកមិនទៀងទាត់ | ភាគច្រើនបិទទ្វារ | ជាទូទៅតែងបិទទ្វារ |
| ១១ | តើប្រជាពលរដ្ឋជាស្ត្រីបានចូលរួមតាមដានរាល់ការសម្រេចចិត្តផ្សេងៗរបស់ឃុំ សង្កាត់ដែរឬទេ? | តែងតែចូលរួម | ភាគច្រើនចូលរួម | ពេលខ្លះចូលរួម | កម្រចូលរួម | មិនធ្លាប់បានចូលរួម |

| លរ | សំណួរ | ☺☺ | ☺ | 😐 | ☹ | ☹☹ |
|---|---|---|---|---|---|---|
| ១២ | តើក្ដារព័ត៌មានឃុំ សង្កាត់ មានបិទព័ត៌មានថ្មីៗដែរឬទេ? | តែងតែមានព័ត៌មានថ្មីៗ | ភាគច្រើនមានព័ត៌មានថ្មីៗ | ពេលខ្លះ | កម្រមានព័ត៌មានថ្មីៗ | មិនមានទាល់តែសោះ |
| ១៣ | តើលោកអ្នកមានការពេញចិត្តកំរិតណាចំពោះការបំពេញការងាររបស់គណៈកម្មការគ្រប់គ្រងគម្រោង? | ខ្ពស់ណាស់ | ខ្ពស់ | មធ្យម | ទាប | មិនមាន |
| ១៤ | តើលោកអ្នកមានការពេញចិត្តយ៉ាងណាដែរ ចំពោះសេវាកម្មដែលឃុំ សង្កាត់ បានផ្ដល់ឱ្យទាក់ទងទៅនឹង ការសុំច្បាប់បរិញ្ញាបនប័ត្រ ការចុះបញ្ជីអត្រានុកូលដ្ឋាន (កំណើត អាពាហ៍ពិពាហ៍ មរណភាព) និងការចុះបញ្ជីផ្សេងៗជាដើម ។ល។ | ខ្ពស់ណាស់ | ខ្ពស់ | មធ្យម | ទាប | មិនមាន |
| ១៥ | តើអ្នកមានការពេញចិត្តកំរិតណាដែរចំពោះដំណោះស្រាយផ្សេងៗរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ? | ខ្ពស់ណាស់ | ខ្ពស់ | មធ្យម | ទាប | មិនល្អទាល់តែសោះ |
| ១៦ | តើមានការប្រជុំនៅក្នុងភូមិរបស់អ្នកទៀងទាត់ដែរឬទេ ដើម្បីរៀបចំបង្កើត និងពិនិត្យឡើងវិញនូវផែនការសកម្មភាព និងផែនការថវិការបស់ឃុំ សង្កាត់ ? | ទៀងទាត់ណាស់ | ទៀងទាត់ | ម្ដងម្កាល | មិនទៀងទាត់ | មិនដែលសោះ |
| ១៧ | តើការអនុវត្តគម្រោងរបស់ឃុំ សង្កាត់ត្រូវបានត្រួតពិនិត្យដោយមានការចូលរួមពីសហគមន៍ដែរឬទេ? | មានការចូលរួមជានិច្ច | ភាគច្រើន | ពេលខ្លះ | កម្រ | មិនមានទាល់តែសោះ |
| ១៨ | តើអ្នកបានដឹងប៉ុណ្ណាដែរអំពីការចំណូល និងចំណាយរបស់ឃុំ សង្កាត់? | ដឹងទាំងអស់ | ដឹងភាគច្រើន | ដឹងផ្នែកខ្លះ | ដឹងបានតិចតួច | មិនដឹងទាល់តែសោះ |

| លរ | សំណួរ | ☺☺ | ☺ | 😐 | ☹ | ☹☹ |
|---|---|---|---|---|---|---|
| ១៩ | តើអ្នកមានការពេញចិត្តយ៉ាងណាដែរចំពោះសេវាកម្មដែលឃុំ សង្កាត់បានផ្ដល់ឱ្យសហគមន៍ទាក់ទងទៅនឹង សុខភាព ការអប់រំ កសិកម្ម ការចិញ្ចឹមសត្វ ជលផល និង ការកសាងផែនការគ្រួសារ ។ល។ | ពេញចិត្តណាស់ | ពេញចិត្ត | មធ្យម | ទាប | មិនពេញចិត្តសោះ |
| ២០ | តើអ្នកមានការពេញចិត្តយ៉ាងណាដែរចំពោះសិទ្ធិទទួលបាន និងប្រើប្រាស់ធនធានសាធារណៈ (ការប្រើប្រាស់ទឹក ការនេសាទ ព្រៃឈើ ដីធ្លី និងវិស័យផ្សេងៗទៀត)? | ពេញចិត្តណាស់ | ពេញចិត្ត | មធ្យម | ទាប | មិនពេញចិត្តសោះ |
| ២១ | តើក្រុមប្រឹក្សាឃុំ សង្កាត់ បានប្រកាសធ្វើបច្ចុប្បន្នភាព (ព័ត៌មានថ្មីៗ) ជាសាធារណៈនូវអត្រាតម្លៃសេវាកម្មដែលកំណត់ដោយរដ្ឋាភិបាលតាមរយៈ (ឧ- ក្ដារព័ត៌មានភូមិ-ឃុំ សមាជិកអង្គការសហគមន៍មូលដ្ឋាន គ.ក.ស ប្រធានភូមិ? | តែងតែប្រកាស | ភាគច្រើនបានប្រកាស | ពេលខ្លះបានប្រកាស | កម្រប្រកាស | មិនដែលប្រកាស |
| ២២ | តើក្រុមប្រឹក្សាឃុំ សង្កាត់មានយកតម្លៃសេវាកម្មផ្សេងៗលើសពីអត្រាតម្លៃដែលបានកំណត់ដោយរដ្ឋាភិបាលដែរឬទេ? | មិនដែលយក | កម្រយក | ធ្វើពេល ខ្លះយក | ភាគច្រើនបានយក | តែងតែយក |

## ឯកសារភ្ជាប់ទី ២

### បញ្ជីសំណួរសម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់វាយតម្លៃការងារអភិបាលកិច្ចមូលដ្ឋាន

### ២.១.តើរដ្ឋបាលមូលដ្ឋានបំពេញមុខងាររបស់ខ្លួនល្អដូចម្តេចដែរ?

| លរ | សំណួរ | ☺☺ | ☺ | 😐 | ☹ | ☹☹ |
|---|---|---|---|---|---|---|
| ១ | តើសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់មានការយល់ដឹងកំរិតណាដែរចំពោះតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន? | ដឹងទាំងអស់ | ដឹងបាន ភាគច្រើន | ដឹងមធ្យម (៥០%) | ដឹងបាន តិចតួច | មិនដឹង ទាំងអស់ |
| ២ | តើការប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ធ្វើឡើងទៀងទាត់ដែរឬទេ? | ប្រជុំជារៀង រាល់ខែ | ភាគច្រើនប្រជុំ ១០-១១ (ដង) ក្នុង១ឆ្នាំ | មានខែខ្លះមិន បានប្រជុំ ៦-៩ ដងក្នុង១ឆ្នាំ | កម្រប្រជុំ ១-៥ ក្នុង១ឆ្នាំ | មិនដែលបាន ប្រជុំសោះ |
| ៣ | តើក្រុមប្រឹក្សាឃុំ សង្កាត់បានផ្សព្វផ្សាយពីលទ្ធផលនៃការប្រជុំខែកន្លងមកដល់សាធារណជនដែរឬទេ? | តែងតែធ្វើ | ភាគច្រើន បានធ្វើ | ធ្វើពេលខ្លះ | កម្រធ្វើ | មិនដែល ធ្វើ |
| ៤ | តើក្រុមប្រឹក្សាឃុំ សង្កាត់បានផ្សព្វផ្សាយជាសាធារណៈដែរឬទេអំពី ប្រធានបទ របៀបវារៈ និងកាលវិភាគប្រជុំ (តាមរយៈក្តារព័ត៌មានភូមិ-ឃុំ សមាជិក គ.ក.ស និងប្រធានភូមិ)? | តែងតែ ផ្សព្វផ្សាយ | ភាគច្រើនបាន ផ្សព្វផ្សាយ | ពេលខ្លះបាន ផ្សព្វផ្សាយ | កម្រ ផ្សព្វផ្សាយ | មិនដែល ផ្សព្វផ្សាយ |

| លរ | សំណួរ | 🙂🙂 | 🙂 | 😐 | ☹ | ☹☹ |
|---|---|---|---|---|---|---|
| ៥ | តើក្រុមប្រឹក្សាឃុំ សង្កាត់បានប្រឹក្សាជាដៃគូជាមួយ ដូចជា (ឧ-មន្ទីរវិស័យ ប្រជាពលរដ្ឋ គ.ក.ស អង្គការសហគមន៍មូលដ្ឋាន អង្គការមិនមែនរដ្ឋាភិបាល អាជីវករ ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំផ្សេងទៀត ....) ក្នុងកំឡុងពេលប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ដែរឬទេ? | តែងតែ ពិភាក្សា | ភាគច្រើនបាន ពិភាក្សា | ពេលខ្លះ ពិភាក្សា | កម្រ ពិភាក្សា | មិនដែល ពិភាក្សា |
| ៦ | តើសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់បានចូលរួមនៅក្នុងការធ្វើសម្រេចចិត្តដែរឬទេ? | បានចូលរួម ទាំងអស់ | ភាគច្រើន ចូលរួម | ភាគតិចបាន ចូលរួម | ១ ឬ ២ ប៉ុណ្ណោះចូលរួម | មានតែមេឃុំ ប៉ុណ្ណោះ |
| ៧ | តើសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ជាស្ត្រីមានឱកាសគ្រប់គ្រាន់ក្នុងការបញ្ចេញមតិនៅក្នុងការ ប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ដែរឬទេ? | បញ្ចេញមតិ គ្រប់គ្រាន់ | បញ្ចេញ មតិច្រើន | បញ្ចេញ មតិខ្លះៗ | កម្រ បញ្ចេញមតិ | មិន បញ្ចេញមតិ |
| ៨ | តើរាល់កំណត់ហេតុនៃការប្រជុំផ្សេងៗរបស់ក្រុមប្រឹក្សាឃុំ សង្កាត់បានកត់ត្រាចែកជូន និងបានពិនិត្យឡើងវិញដែរឬទេ? | តែងតែអនុវត្តន៍ | ភាគច្រើន បានអនុវត្តន៍ | ពេលខ្លះ អនុវត្តន៍ | កម្រ អនុវត្តន៍ | មិនដែល អនុវត្តន៍ |
| ៩ | តើរាល់ការសម្រេចចិត្តរបស់ក្រុមប្រឹក្សាឃុំ សង្កាត់បានយកទៅអនុវត្តដែរឬទេ? | តែងតែធ្វើ | ភាគច្រើន បានធ្វើ | ធ្វើពេលខ្លះ | កម្រធ្វើ | មិនដែលធ្វើ |
| ១០ | តើសាលាឃុំ សង្កាត់បើកបំរើការងារជាទៀងទាត់ដែរឬទេ? | បើកជារៀងរាល់ថ្ងៃ និងទៀងទាត់ | បើក ៤ ថ្ងៃ ក្នុង ១ សប្តាហ៍ | បើកមិនសូវ ទៀងទាត់ | បិទភាគច្រើន | តែងតែបិទ |

| លរ | សំណួរ | 😊😊 | 😊 | 😐 | ☹ | ☹☹ |
|---|---|---|---|---|---|---|
| ១១ | តើក្តារព័ត៌មានឃុំ សង្កាត់មានបិទព័ត៌មានថ្មីៗដែរឬទេ? | តែងតែបិទព័ត៌មានថ្មីៗ | ភាគច្រើនបានបិទព័ត៌មានថ្មីៗ | បានបិទពេលខ្លះ | កម្របានបិទព័ត៌មានថ្មីៗ | មិនបានបិទទាល់តែសោះ |
| ១២ | តើការចុះបញ្ជី និងកំនត់ត្រានានាត្រូវបានរក្សាទុក និងធ្វើបច្ចុប្បន្នភាព( ព័ត៌មានថ្មី ឬទាន់ហេតុការណ៍) ដែរឬទេ?<br>ឧ. - របាយការណ៍រីកចំរើននៃការអនុវត្តគម្រោង<br>- ដីកាឃុំ សង្កាត់/គោលការណ៍ណែនាំផ្សេងៗពីក្រសួង និង សេចក្តីសម្រេចចិត្តរបស់ឃុំ សង្កាត់ | រាល់ការចុះបញ្ជី និងកំនត់ត្រា សំខាន់ត្រូវបានទុកដាក់ និងធ្វើបច្ចុប្បន្នភាព | រាល់ការចុះបញ្ជី និងកំនត់ត្រា សំខាន់ត្រូវបានទុកដាក់ និងមិនបានធ្វើបច្ចុប្បន្នភាព | រាល់ការចុះបញ្ជី និងកំនត់ត្រា សំខាន់មិនបានទុកដាក់ ប៉ុន្តែបានធ្វើបច្ចុប្បន្នភាព | រាល់ការចុះបញ្ជី និងកំនត់ត្រា សំខាន់មិនបានទុកដាក់ មិនបានធ្វើបច្ចុប្បន្នភាព | គ្មានការចុះបញ្ជី និងកំនត់ត្រា សំខាន់ត្រូវបានទុកដាក់ |
| ១៣ | តើគណៈកម្មាធិការផែនការ និងថវិកា គណៈកម្មាធិការលទ្ធកម្ម គណៈកម្មាការដោះស្រាយទំនាស់ គណៈកម្មាធិការគ្រប់គ្រងគម្រោង និងជនបង្គោលត្រួតពិនិត្យវាយតម្លៃគម្រោងកំពុងបំពេញមុខងារបានល្អដែរឬទេ? | កំពុងបំពេញមុខងារបានល្អ | ភាគច្រើនបានបំពេញមុខងារ | ភាគខ្លះបានបំពេញមុខងារ | មានតិចតួចបំពេញមុខងារ | មានត្រឹមតែនៅលើក្រដាសប៉ុណ្ណោះ |
| ១៤ | តើការប្រជុំរៀបចំផែនការ និង ថវិការបស់ក្រុមប្រឹក្សាឃុំ សង្កាត់បានធ្វើឡើងជាសាធារណៈដែរឬទេ? | បានធ្វើឡើងជាសាធារណៈក្នុងមូលដ្ឋានរបស់ប្រជាពលរដ្ឋ | មានតែការប្រជុំពិគ្រោះយោបល់ត្រូវបានធ្វើ | មានតែការប្រជុំសារធារណៈបានធ្វើឡើងនៅថ្នាក់ឃុំ សង្កាត់ | មិនមានការប្រជុំសារធារណៈត្រូវបានធ្វើឡើងទេ | មិនមានការចូលរួមរបស់ប្រជាពលរដ្ឋ |

| លរ | សំណួរ | ☺☺ | ☺ | 😐 | ☹ | ☹☹ |
|---|---|---|---|---|---|---|
| ១៥ | តើចំណូល និងចំណាយថវិការបស់ឃុំ សង្កាត់បានបិទប្រកាសជាសាធារណៈឬទេ? | ថវិកាត្រូវបានបង្ហាញនិងចែកជូនក្នុងពេលប្រជុំជា សាធារណៈ | ថវិការត្រូវបានបង្ហាញតែមិនបានចែកជូន | ថវិកាមិនត្រូវបានបង្ហាញជាអចិន្ត្រៃយ៍នោះទេ | ថវិកាមិនត្រូវបានបង្ហាញតែប្រជាពលរដ្ឋអាចសួរបាន | ថវិកាមិនត្រូវបានបិទផ្សាយ |
| ១៦ | តើក្រុមប្រឹក្សាឃុំ សង្កាត់ធ្វើដូចម្តេចដើម្បីធានាតម្លាភាពក្នុងការរៀបចំកិច្ចលទ្ធកម្ម និងផ្តល់កិច្ចសន្យាគម្រោង? | ប្រជាពលរដ្ឋទាំងអស់បានចូលរួម | ប្រជាពលរដ្ឋភាគច្រើនបានចូលរួម | ប្រជាពលរដ្ឋខ្លះបានចូលរួម | ប្រជាពលរដ្ឋភាគតិចចូលរួម | ប្រជាពលរដ្ឋមិនបានចូលរួម |
| ១៧ | តើសហគមន៍បានចូលរួមតាមដានការអនុវត្តគម្រោងដែរឬទេ? | តែងតែចូលរួម | ភាគច្រើនបានចូលរួម | ធ្វើពេលខ្លះបានចូលរួម | កម្របានចូលរួម | មិនដែលចូលរួម |
| ១៨ | តើឃុំ សង្កាត់ធ្លាប់រមានសវនកម្មឯករាជ្យប្រចាំឆ្នាំដែរឬទេ? បើមាន តើលទ្ធលផលរកឃើញបានចែកជូន និងប្រកាសជាសាធារណៈដែរឬទេ?. | សវនកម្មឯករាជ្យតែងតែធ្វើ និងចែករំលែក | សវនកម្មឯករាជ្យ តែងតែធ្វើ តែមិនចែករំលែក | សវនកម្មឯករាជ្យធ្វើមិនទៀងទាត់ | សវនកម្មឯករាជ្យកម្រធ្វើ | មិនដែលមានសវនកម្មឯករាជ្យ |

| លរ | សំណួរ | ☺☺ | ☺ | 😐 | ☹ | ☹☹ |
|---|---|---|---|---|---|---|
| ១៩ | តើក្រុមប្រឹក្សាឃុំបានប្រកាស (ធ្វើបច្ចុប្បន្នភាព) ជាសាធារណៈពីអត្រាតម្លៃសេវាកម្មដែលកំណត់ដោយរដ្ឋាភិបាលតាមរយៈ (ឧ- ក្តារព័ត៌មានភូមិ-ឃុំ សមាជិក គ.ក.ស ប្រធានភូមិ? | តែងតែប្រកាស | ភាគច្រើនបានប្រកាស | ពេលខ្លះបានប្រកាស | កម្រប្រកាស | មិនដែលប្រកាស |
| ២០ | តើក្រុមប្រឹក្សាឃុំ សង្កាត់មានយកតម្លៃសេវាកម្មផ្សេងៗលើសពីអត្រាតម្លៃដែលបានកំណត់ដោយរដ្ឋាភិបាលដែរឬទេ? | មិនដែលយក | កម្រយក | ធ្វើពេលខ្លះយក | ភាគច្រើនបានយក | តែងតែយក |
| ២១ | តើប្រជាពលរដ្ឋជាស្ត្រីបានចូលរួមតាមដានរាល់ការសំរេចចិត្តផ្សេងៗនៅថ្នាក់ឃុំ សង្កាត់ដែរឬទេ? | តែងតែចូលរួម | ភាគច្រើនបានចូលរួម | ពេលខ្លះបានចូលរួម | កម្រចូលរួម | មិនដែលចូលរួម |
| ២២ | តើក្រុមប្រឹក្សាឃុំ សង្កាត់មានគណនេយ្យភាព និង តម្លាភាពដូចម្តេចខ្លះក្នុងការធ្វើការសម្រេចចិត្តជាសាធារណៈ? | ដោយពេញលេញ | ភាគច្រើន | ពេលខ្លះ | មិនពេញលេញ | មិនដែលធ្វើ |
| ២៣ | តើក្រុមប្រឹក្សាឃុំបានរៀបចំកិច្ចប្រជុំសម្របសម្រួលរវាងរដ្ឋាភិបាល និង អង្គការមិនមែនរដ្ឋាភិបាលទៀងទាត់ដែរឬទេ? | ធ្វើជាទៀងរាល់ខែ | ភាគច្រើន ១០-១១ ក្នុង១ឆ្នាំ | មានខ្លះ៦-៩ ក្នុង១ឆ្នាំ | កម្រ១-៥ ក្នុង ១ឆ្នាំ | មិនដែលធ្វើសោះ |
| ២៤ | តើប្រជាពលរដ្ឋជាស្ត្រីមានការចូលរួមសំដែងមតិកម្រិតណានៅក្នុងកិច្ចប្រជុំនានារបស់ក្រុមប្រឹក្សាឃុំ សង្កាត់? | ខ្ពស់ណាស់ | ខ្ពស់ | មធ្យម | ទាប | មិនមាន |

| លរ | សំណួរ | ☺☺ | ☺ | 😐 | ☹ | ☹☹ |
|---|---|---|---|---|---|---|
| ២៥ | តើប្រជាជនក្រីក្រ និងជនមិនសូវមានតំណាងមានការចូលរួមកំរិតណានៅក្នុងកិច្ចប្រជុំនានារបស់ក្រុមប្រឹក្សាឃុំ សង្កាត់? | ខ្ពស់ណាស់ | ខ្ពស់ | មធ្យម | ទាប | មិនមាន |

## ២.២. តើប្រជាពលរដ្ឋចូលរួមបានល្អដូចម្តេចដែរចំពោះអភិបាលកិច្ចមូលដ្ឋាន?

| លរ | សំណួរ | ☺☺ | ☺ | 😐 | ☹ | ☹☹ |
|---|---|---|---|---|---|---|
| ២៦ | តើប្រជាពលរដ្ឋមានការយល់ដឹងដូចម្តេចដែរចំពោះតួនាទី និងការទទួលខុសត្រូវរបស់ខ្លួននៅក្នុងការចូលរួមអភិវឌ្ឍន៍ និងសកម្មភាពផ្សេងៗទៀតរបស់សហគមន៍? | ដឹងទាំងអស់ | ដឹងបានភាគច្រើន | មធ្យម | ដឹងបានតិចតួច | មិនដឹងទាំងអស់ |
| ២៧ | តើកម្រិតនៃការចូលរួមរបស់ប្រជាពលរដ្ឋសាមញ្ញក្នុងការប្រជុំសាធារណៈទូទៅមានលក្ខណៈដូចម្តេចដែរ? | ខ្ពស់ណាស់ | ខ្ពស់ | មធ្យម | ទាប | មិនមាន |
| ២៨ | តើកម្រិតនៃការចូលរួមរបស់ស្ត្រីក្នុងការប្រជុំសាធារណៈទូទៅមានលក្ខណៈដូចម្តេចដែរ? | ខ្ពស់ណាស់ | ខ្ពស់ | មធ្យម | ទាប | មិនមាន |
| ២៩ | តើកម្រិតនៃការចូលរួមរបស់ប្រជាជនក្រីក្រ និងជនមិនសូវមានតំណាងក្នុងការប្រជុំសាធារណៈមានលក្ខណៈដូចម្តេចដែរ? | ខ្ពស់ណាស់ | ខ្ពស់ | មធ្យម | ទាប | មិនមាន |

## ឯកសារភ្ជាប់ទី ៣ ទម្រង់ផែនការសកម្មភាពដើម្បីលើកកម្ពស់អភិបាលកិច្ចល្អនៅមូលដ្ឋាន

| បញ្ហា | ដំណោះស្រាយ | អ្នកទទួលខុសត្រូវ | អ្នកគាំទ្រពីខាងក្រៅ | ថវិកា | ពេលវេលាកំណត់ | ឯកសារ ភស្តុតាង |
|---|---|---|---|---|---|---|
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

**ផលិតដោយ**

Pact Cambodia

មជ្ឈមណ្ឌលភ្នំពេញ ជាន់ទី៣ កែងផ្លូវព្រះស៊ីហនុ ២៧៤) និងមហាវិថីព្រះសុធារស

សង្កាត់ទន្លេបាសាក់ ខណ្ឌ ចំការមន រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខ ១៤៩

ប្រៃសណីយ៍ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ (៨៥៥-២៣) ២១៧ ៨៥៥ ទូរសារ (៨៥៥-២៣) ២១៧ ៨៥៦

www.pactcambodia.org

**សហការផលិតដោយ**

**ក្រសួងមហាផ្ទៃ**

**សម្ព័ន្ធភាពជាតិឃុំ សង្កាត់**
**នៃព្រះរាជាណាចក្រកម្ពុជា**

**ឧបត្ថម្ភដោយ**

USAID
FROM THE AMERICAN PEOPLE

ការបោះពុម្ពនេះអាចធ្វើទៅបាន ដោយមានការជួយឧបត្ថម្ភគាំទ្រពីសំណាក់ប្រជាពលរដ្ឋអាមេរិក តាមរយៈទីភ្នាក់ងារសហរដ្ឋអាមេរិកសំរាប់ការអភិវឌ្ឍន៍អន្តរជាតិ (USAID) ។ គំនិតដែលបានសរសេរនៅក្នុងឯកសារនេះ គឺជាការទទួលខុសត្រូវរបស់អង្គការផេកកម្ពុជា ហើយមិនឆ្លុះបញ្ចាំងទស្សនៈរបស់ USAID ឡើយ ។

**សៀវភៅជំនួយស្មារតីស្តីពី ដំណើរការពង្រឹងការងារអភិបាលកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់**

បោះពុម្ពលើកទី ១

© កញ្ញា ២០១០